# សុត្រុកទេវ

## ភាគ ៣




B-8
D-80
N° 184
ARCHIVES ... COTE
DÉPOT LÉGAL
140

# រឿងសុគន្ធបោង

## វគ្គ ៣

រៀបរៀងសម្រួលតាមច្បាប់ដើម

ចាត់ការបោះពុម្ព - សុជីវក

ផ្សាយចេញពី

ARCHIVES NATIONALES
RÉGIE DU DÉPOT LÉGAL

ARCHIVES NATIONALES
COTE
B-114-1359 8°

បណ្ណាគារសុជីវក

លេខ ១៩ វិថីព្រះបាទត្រសក់ផ្អែម ភ្នំពេញ

លេខ ១៩ - ខាងត្បូងផ្សារធំថ្មី

ព.ស. ២៤៩៩ គ.ស. ១៩៥៧

រក្សាសិទ្ធិ

សាធារណរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ
លេខក្ដិ :
លេខបញ្ជី

មនោម័យគេចវៃម្នីម្នា ទាំងដៃជាប់ជា ស្មៀនវាយពុំទាន់ឡើយ ណា ៗ មេក្លូលែងគ្នាហើយប្រវារ ប៉ងចាប់អាសារ ពាជីឲ្យបានដូចចិត្ត ៗ រាជអាជនេយ្យខ្លាំងក្លាត់ ស្វាញស្ទុះ លែងស្គាត់ ដាក់ប្រំមេយក្ខិនី ៗ រីឯនៃមេសម្ពុរី ស្វាញ ស្ទុះឡើងខ្ពី ប្រយុទ្ធនឹងស្ដេចអាសុពាហ៍ ៗ សឹងខ្លាំង កម្លាំងស្មើគ្នា ទឹងពានទឹងពារ ទៅវិញទៅមកពុំបាន ៗ កក្រើកកំរើកសព្វហាន ជ្រាបដល់ក្សត្រក្សាន្ត ព្រះបាទ សាមលដៀស្ដៃ ៗ ត្រាស់ប្រើជ័យសូរិន្ទ្រនៃ ឲ្យយកខាន់ ជ័យ ទៅផ្ចាញជីវិតយក្សា ៗ ពារជីទទួលឧង្ការ ហើយ ទ្រង់ខាន់ថ្វា យាត្រាទៅដល់ហើយហោង ៗ ព្រះបាទ ព្រហ្មទត្តប្រាស់ប្លង យល់ឃើញហើយហោង ស្ដេចមាន បន្ទូលឃាត់ថា ៗ កុំអ្នកតទង់យក្សា អំបាលបិតា ធ្វើការទឹងវ៉ាពុំបាន ៗ ទើបពោធិសត្វទូលបាន ថាខ្ញុំគាបហ៊ាន យកឈាមទៅលាបមាតា ៗ កុំបីព្រះគុណគិតថា ក្រែងខ្ញុំ នេះណា ពុំបានទឹងយក្ខនោះនៃ ៗ ស្រេចហើយអ្នកបរជូលវៃ

ហៅទៅអាជានេយ្យ ឲ្យលែងតទឹងយក្សា ៗ ហើយមានបន្ទូល ទៅថា អញមកហើយណា សឹមអញសម្លាប់វាហោង ៗ យក្សឮកុមារសោសង់ ពោលពាក្យឆ្នោះហោង យក្ខស្រើងឹត ខឹងក្រៃ ៗ យក្ខថាក្មេងប៉ុនមេដៃ ពោលពាក្យធំក្រៃ ថា នឹងសម្លាប់អញណា ៗ យក្ខដោះដៃពីអាសារ ស្ទុះទៅប្រវា លោចាប់ពោធិសត្វថ្វៃ ៗ ពោធិក្រឡះរិលវៃ វ៉ែរព្រះ ខាន់ជ័យ ទៅត្រូវនៃក្បាលយក្សា ៗ សន្ទប់ដួលលើគ្រ ឡា ប្រថពីហើយណា កុមារហៅបិតាខ្ញុំ ៗ ទៅយក ពានមាសមកនៃ ដាក់ឈាមខេណី ដែលស្លាប់នឹងដៃខ្ញុំណា ៗ ស្តេចយកពានសុវណ្ណា ឲ្យទៅកុមារ ដាក់នៃឈាមយក្ខនោះ ហោង ៗ កុមារអ្នកអាស្វគ្គ យក្ខក្ស័យហើយហោង ៗ យក ឈាមដាក់កាដ៍នមាសមៃ ៗ ស្រេចហើយពោធិចាប់វៃ យក ពានមាសនៃ ទៅថ្កានព្រះវរបិតា ៗ ដល់ហើយបង្គំទូលថា ក្រាបលាបិតា នឹងនាំយកឈាមយក្ខទៅ ៗ លាបព្រះមាតា អ្នកនៅ ម្នាក់ឯងក្រែងទៅ រកអ្នកពុំជួបឡើយណា ៗ កាល

មកអ្នកបានផ្តាំថា ថ្ងៃត្រង់នោះណា ឲ្យខ្ញុំនេះបានដល់ទៅៗ ឥឡូវនេះមកយូរនៅ ពុំឃើញដល់ទៅ ម៉្លេះអ្នកទទឹងណាស់ហោង ៗ កាលនោះព្រះបាទចប្បាស់ច្បង ស្តាប់បុត្រសាសង ទូលណាប្រញាប់ព្នោះណា ៗ ស្តេចមានបន្ទូលឃាត់ថា អ្នកចាំបិតា នឹងយកអស់ស្រីស្នំផង ៗ ទៅទទួលនាងមកហោង យានដំរិះផង ឲ្យមានទាំងព្រមទៅនៃ ៗ បន្ទូលអន់អួលព្រះទ័យ ទើបព្រះជៀស្ឋជ័យ ត្រាស់ប្រើអស់ទាំងសេនា ៗ ឲ្យរៀបប្រដាប់ប្រដា ឲ្យគ្រប់គ្នាណា ហើយឲ្យមានមងអញ្ជួង ៗ សម្រាប់ឲ្យមានទៅផង ឲ្យឆាប់ៗហោង នឹងទៅឥឡូវនេះណា ៗ កាលនោះឯអស់សេនាទទួលឱង្ការ រៀបស្រេចដូចបង្គាប់នៃ ៗ រីឯព្រះបាទជៀស្ឋជ័យ នាំបុត្រានៃ ទៅឋានព្រះវរបិតា ៗ ដល់ហើយបង្គំទូលថា ក្រាបណាបិតា ទៅទទួលនាងនាថនៃ ៗ ព្រះបាទសាមលជៀស្ឋជ័យ ស្តេចទ្រង់ត្រាស់វៃ ថាអញនេះទៅដែរហោង ៗ ទាំងនាងចន្ទរក្ខាផង នាងទៅ

ដែរហោង អស់ស្ងំសៅដៃនោះណា ៗ កាលនោះ ទាំងពីរក្សត្រា នាងចន្ទវេក្ខា សឹងព្រមមូលមួយព្រះទ័យៗ ទឹងចៅទាំងពីរនោះនៃ លើកយោធាវៃ ចេញទៅពុំយូរឡើយណា ៗ មូលមួយទឹងស្ងំក្រុមការ សេទីយ៍សេនា យោធាអាមាត្យនោះហោង ៗ និទានពីក្សត្រច្បាស់ច្បង ទឹងកុមារផង ស្ងួះទុកនៅនេះក្សិណណា ៗ ទឹងនិទានពីកញ្ញា សុគន្ធាថានណា កាលក្រោយកុមារនោះនៃ ៗ នាងនៅម្នាក់ឯងក្នុងព្រៃ លង់លុះដល់ថ្ងៃ ទៀបគ្រប់នាងនាថគនិដ្ឋា ៗ រំពៃគយគន់បុត្រា ពុំយល់ឡើយណា លុះដល់រសៀលហើយហោង ៗ នាងរឹងទ្រូងកន្ទួង យល់បុត្របាត់ហោង ប្រាសប្រាណគីលាកថ្ងៃងថា ៗ ឱកូនគូកែវមាតា នាំប្អូនទៅផ្សារ ទៅអ្វីបាត់យូរម្ល៉េះនៃ ៗ កាលព្រាហ្មនាំទៅឆាប់នៃ ឥឡូវនេះនៃ ថ្ងៃរសៀលណាស់ទៅហើយ ៗ ពុំឃើញមុខមាសមកឡើយ កូនកែវម្ដាយអើយ ក្រែងអ្នកវង្វេនផ្លូវ

ណា ៗ ពុំចាំផ្លូវដែលយាត្រា ទៅពីមុនណា ព្រាហ្ម នាំយាត្រានោះហោង ៗ ដើរជ្រួសទៅឆ្ងាយកន្ទង់ ទើប បាត់ម្ទេះហោង កែវម្ដាយវង្វេងទៅណា ៗ កាលទៅ ម្ដាយបានផ្ដាំថា ថ្ងៃត្រង់នោះណា ឲ្យបានវិលមកដល់ ហោង ៗ ឥឡូវបាត់យូរកន្ទង់ ថ្ងៃល្ងាចហើយហោង ពុំឃើញកែវម្ដាយមកឡើយ ៗ បាត់ម្ទេះនេះវង្វេងហើយ កូនកែវម្ដាយអើយ នាំបួនដើរទៅឯណា ៗ ពើបពះពួក សត្វម្រឹគហ្វូង ពានជួបអ្នកណា ប្រហារជីវិតទៅហើយ ៗ នាង ទន្ទឹងបុត្រត្រាណាត្រើយ វិតក្កតទៀតហើយ ចូល គ្របសព៌ក្នុងអង្គកាយ ៗ ព្រើលចិត្តក្ដុកក្ដួលសោកស្ដាយ មន្ទ យក្ខនាំក្លាយ កាយទៅជាទោចសោះសា ៗ លោតឡើង លើមែកព្រឹក្សា ដូនជាក្សត្រា កុមារទាំងពីរទៅផង ៗ ទាំង អង្គព្រះបាទសាមល ទេពីស្នំផង ដួបជុំសេនាយោធា ៗ សឹងមើលឃើញនាងនាថណា ទាំងអស់គ្រប់គ្នា ពុំយល់ជានាង នាថឡើយ ៗ មើលឃើញតែជាទោចហើយ ទើបក្សត្រ

ត្រាណត្រើយ ត្រាស់សួរពោធិសត្វថា ។ តោចនេះនឹង
ហើយមាតា ឬមិនមែនណា មាតាទៅឯណាហើយ ទើបពោធិ
សត្វត្រាណត្រើយ ថាព្រះគុណអើយ ព្រះអង្គត្រូវមន្តយក្សៗ
មើលទៅពុំស្គាល់ឡើយណា នឹងហើយមាតា វក់ធ្លុតជួប
តោចនោះហោង ។ សូមប្រើឲ្យអស់ស្រីផង ទៅក្រោម
នោះហោង រើសផ្កាផ្លែមាសនោះណា ។ ជ្រុះចុះមក
ក្រោមព្រឹក្សា តែដូច្នោះណា រៀងរាបដាបមកហោង ។
ឯព្រះនរនាថច្បាស់ច្បង ទ្រង់ជ្រាបហើយហោង ត្រាស់
ប្រើអស់ស្រីនេះណា ។ ស្រីផងទទួលឱង្កា នៃមហា
ក្សត្រា ហើយទៅដល់ក្រោមនាងហោង ។ កាលនោះសុ
គន្ធជោងទួនល្អង យល់អស់ស្រីផង ដើរចូលមកក្រោមនាង
ណា ។ នាងនាថគិតភ័យតក្កមា ហើយហាមាត់ថា ឲ្យ
គេមកចាប់អញហោង ។ បន្ទូលស្រេចហើយទួនល្អង ផ្កា
ផ្លែមាសហោង ជ្រុះចុះមកក្រោមព្រឹក្សា ។ ឯអស់
ស្រីផងនោះណា ដណ្តើមរើសផ្កា ផ្លែមាសនៅក្រោម

នាងនៃ ៗ ឯនាងនាថចាំងគិតភ័យ ទតទៅយល់នៃ អស់
ទាំងយោធាសេនា ៗ នាងគិតភ័យអន្ទះសា ពុំនៅនោះ
ណា ស្ទុះទៅឃើមួយទៀតនៃ ៗ ឯអស់ស្រីផងវិលវៃ
យកផ្កាថ្កុលនៃ ទៅថ្វាយព្រះមហាក្សត្រា ៗ ស្តេចបាន
ទតជាក់ហើយណា ទើបមហាក្សត្រា ឲ្យអស់យោធា
នោះនៃ ៗ លើកគ្នាទៅព្រួតកាប់ព្រៃ ព័ទ្ធជុំវិញនៃ
កុំឲ្យនាងនាថធីតា ៗ លោតទៅទីឆ្ងាយឡើយណា ឯអស់
សេនា ទទួលបង្គាប់ហើយហោង ៗ នាំអស់យោធាពល
ផង ព័ទ្ធកាប់ឈើហោង ជុំវិញនៃនាងនោះណា ៗ ស្រេច
ហើយស្តេចបង្គាប់ថា ឲ្យអស់សេនា យកមងទៅពាស
ក្រោមហោង ៗ ពាសស្រេចសូរេចហ៊ុតហ៊ុង ហើយយក
អន្ទង់ ទៅព្រួតលើមងទៀតណា ៗ ប្រុងប្រយ័ត្នក្រែងធីតា
លោតចុះមកណា ឲ្យទើរលើមងនោះហោង ៗ ឯសុគុណ
ថោងទទួនល្អង ភ័យពេកក្តាត់ហោង ក្រែងគេសម្លាប់នាងណា ៗ
នាងមើលទៅយល់ក្សត្រា យល់ទាំងកុមារ នោះនាងពុំស្គាល់

ឡើយហោង ។ រីឯកិតរឹងក័យកន្ទង់ ក្តួចនឹកកូនហោង ដូច
តោចវិស័យសោះសា ។ កាលនោះព្រះបាទក្សត្រា ប្រើ
អស់សេនា ឡើងទៅដាក់នាងនោះហោង ។ នាងនាថ
រីឯកិតកន្ទង់ ឃើញគេនោះហោង ឡើងទៅដូច្នោះហើយ
ណា ។ នាងស្ទុះលោតលើព្រឹក្សា របូតហត្ថា ធ្លាក់មកទើរ
លើមងនៃ ។ ពោធីឮហើយឆាប់វៃ យកឈាមយក្សនៃ
ទៅលោបអង្គព្រះមាតា ។ នាងនាថពុំដឹងកាយា ក្តឹកក្តួច
ខ្លួនណា សូន្យស្មុងវិញ្ញាណនាងហោង ។ ពោធិសត្វ
លើកត្រកង មាតាឡើងហោង ហើយលាបឈាមយក្ខទៀត
ណា ។ ស្រឡាបលាបសព្វកាយា មន្តយក្សនោះណា
ស្បើយអស់ពីអង្គនាងហោង ។ ឆោមឆើតល្អល្អះឥតហ្មង
ដូចពីដើមហោង ឥតមានសៅហ្មងឡើយណា ។ កាល
នោះនាងបន្ទូរក្ខា អស់ស្រីនោះណា មើលទៅស្គាល់ជា
នាងនៃ ។ ព្រះបាទសោមលជៀស្ផៃ ទតយល់នាងនៃ
ក៏ស្គាល់ជាព្រះសុណិស្សា ។ ព្រះបាទព្រហ្មទត្តនោះណា

យល់អគ្គកន្និដ្ឋា នោះជាដូចពីដើមនៃ ៗ ញ័រញើមក្តុកក្តួលព្រះទ័យ គិតពីកាលនៃ ស្តេចឲ្យព្រះរាជកុមារ ៗ ចេញទៅតាមព្រះមាតា ទឹកកាលក្សត្រា ទតយល់រ័ត្នន្ធល្អ ៗ សុទ្ធដូចសត្វទោចនោះហោង ម៉្លោះហើយច្បាស់ច្បង ប្រាសប្រាណកិលាកជាម្តង ៗ មិនដឹងជាធ្វើមធ្វើបង យក្ខចាប់នាងហោង ចោលទៅត្រូវមន្តយក្សា ៗ ឲ្យទៅជាទោចនោះណា គេជ:កុមារ មានរិទ្ធិត្រូវមន្តយក្ខ ៗ មើលឃើញហើយបានស្គាល់ជាក់ ថានាងជាយក្ខ ហើយប្រឹងរត់យំតាមទៅ ៗ បានមូលនឹងកូននោះក្ងួ ហើយកុមារទៅ បានជួបតាសីទ្ធផ្សារ ៗ នេះព្រោះតែបានបុត្រា ជ័យសុរិន្ទ្រា ផ្ចាញយក្ខយកឈាមមកបាន ៗ លាបប្អូនមិត្រមាសកល្យាណ ធ្វើមធ្វើបងបាន រូបរស់ជាមនុស្សវិញណា ៗ សោកហើយខុនខុបកន្និដ្ឋា ក្តឹកក្តួចព្រះស្មា រតីផល់សន្ធប់ហោង ៗ ឯសុខន្ធ:ថោងទន់ល្អ សោកសន្ធប់ហោង ព្រមទាំងអង្គព្រះភស្តា ៗ កាលនោះចាំងពីកុមារ ទាំងព្រះ

ផុទសា ម៉ែលនាងចន្ទរេក្ខាផង ៗ យល់ហើយកុមារកិតភ័យ យកគត្តាវៃ លុបលាមកក្រ្តាពីរក្សត្រ ៗ ផ្ទានដឹង ស្មារតីឡើងថ្វាត់ សុគន្ធថោងរូបរ័ត្ន បង្គំមាតាបិតា ៗ កាលនោះនាងចន្ទរេក្ខា យល់បុត្រសុណិស្សា ដឹងស្មារតី បង្គំហោង ៗ នាងយកហត្ថាទាំងសង ឱបសុណិស្សា ហោង ហើយមានសុវណ្ណីស្ស្វរថា ៗ កូនអើយកូនអង្គកាយា នាងតើម្ដេចណា ស្រឡះជ្រះហើយម្ដងទៅ ៗ នាង នាថសុគន្ធថោងទូលទៅ ថាខ្ញុំឥឡូវ ស្រឡះអស់អង្គ ហើយណា ៗ ព្រះផុទសាមលក្សត្រា នាងចន្ទរេក្ខា យល់ន័យសុណិស្សាហើយ ៗ អរឥតមានក្សីស្មើឡើយ ទើបក្សត្រត្រាណត្រើយ ប្រជុំអស់ពលយោធា ៗ សូរេច ស្រាប់ស្រេចពជា យកគជ្ជន្ទ្រា ទីនាំនៃបុត្រនោះ ហោង ៗ ចងគ្រឿងគ្រប់ស្រេចឥតហ្មង កូបកញ្ចោង ហោង សន្ធិយាឲ្យចងស្រេចនៃ ៗ ៗ ទើបមហាក្សត្រា ជៀស្តដៃ ឲ្យនាងនាថនៃ ឡើងគង់ទីនព្រះមាតា ៗ

រីឯទាំងពីរកុមារ ឡើងគង់គជសា ព្រះរាមអនុជនោះនៃ ៗ ព្រះបាទសាមលជៀស្ដដៃ ស្តេចឡើងគង់នៃ ទីនាំងរាជា រដ្ឋ ៗ ព្រះបាទព្រហ្មទត្តនោះណា ឡើងគង់រដ្ឋ ទន្ទឹម អសុតាហ៍នោះនៃ ៗ រីឯស្រីស្នំសៅដៃ ស្តេចទ្រង់ជិះនៃ រាជរថ គ្រប់គ្នានោះណា ៗ ឯអស់ពាហានកាសារ មន្ត្រីសេនា យោធាអាមាត្យនោះនៃ ៗ រៀបហែព្រះបាទជៀស្ដដៃ តាមក្បួន ហើយនៃ ស្រាប់ស្រេចពុំលង់ម្មីម្មា អស់ទាំងមន្ត្រីយោធា ហែ ព្រះរាជា បានដល់ចូលក្នុងកំពង់វៃ ៗ ដល់ហើយព្រះបាទ ជៀស្ដ ដៃ អស់ស្នំនោះនៃ បុះចាកព្រះរាជរដ្ឋ ៗ ព្រមទាំងអង្គ ព្រះ កុមារ បុះចាកគជសា ព្រះរៀមអណុជនោះហោង ៗ នាងនាថ សុគន្ធថោងទួនល្អង ទឹងមាតាហោង បុះចាកពីគជេន្ទ្រា ៗព្រះ បាទសាមលរាជា នាងចន្ទរក្ខា ស្តេចគង់អាសនាលើហោង ៗ ព្រហ្មទត្តសុគន្ធថោងទួនល្អង អាសនាមួយហោង គង់គាល់ ទាំងបួនអង្គក្សត្រ ៗ កាលនោះឯអង្គព្រះបាទ សាមលនរនាថ ទ្រង់ត្រាស់បង្គាប់ទៅថា ៗ ឡុម្ពកពិសេសនោះណា រៀប

ភោជន៍អាហារ ទឹងចង់ហត្ថានាងហោង ៗ កាលនោះភ្នក

ពិសេសហោង ពុក្យត្រប្រាស់ច្បង ទ្រង់ត្រាស់បង្គាប់ភ្នា:

ហើយ ៗ ពិតពុំបង្អង់យូរឡើយ រៀបរួចស្រេចហើយ

លើកយកមកថ្វាយឆាប់ថ្វាត់ ៗ

បទកាគតិ រីកាលនោះនៃ ឯអស់មន្ត្រី ដែលទៅរក្សា ក្នុង

ព្រះរាជវាំង ឃើញខ្មោចយក្ស ហើមស្អុយហើយណា នាំភ្នាក់

ផ្អើលផង ៗ អូសខ្មោចយក្ស យកទៅចោលណា ពុំរួចឡើយ

ហោង ទើបបានឲ្យកែណ្ណ អស់ទាំងពលផង ១ពាន់ទៀតហោង

អូសពុំរួចឡើយ ៗ ដង្កៀតខ្មោចយក្ស ទាំងពុមាក ទៅយក

ចោលហើយ ពលអូសមួយពាន់ ពុំរួចបានឡើយ អូសអស់

ចិត្តហើយ ក៏ពុំរួចណា ៗ កាលនោះមន្ត្រី ទូនរាបសារសើ

បង្គំទូលថា បពិត្រយើងខ្ញុំ យកពលមកណា អូសខ្មោច

យក្ស ពុំកម្រើកឡើយ ៗ ទើបមហាក្សត្រថ្លៃ ចប់ក្នុងព្រះទ័យ

ក្រែងទាំងក្សត្រហើយ ទៅអូសវិញណា ស្តេចបន្ទូលធ្វើយ

ប្រើអាមាត្យហើយ ទៅហៅបុត្រា ៗ អាមាត្យបាន

ស្តាប់ បង្គំលាឆាប់ ហៅព្រះកុមារ ថាម្ចាស់ថ្លៃអើយ ឥឡូវក្សត្រា ឲ្យអ្នកយាត្រា ទៅឥឡូវហោង ។ កាលនោះពោធិ៍ ចៅចមមូលី សត្វសាងបរមី ពុទ្ធាសីទូល ដូច្នោះហើយនៃ ពោធិ៍នរបតី យកព្រះខ័ន្ធថ្វា ។ ដែលសម្លាប់យក្ស ដូរជាតិអប្បលក្ខណ៍ យកឈាមវាណា បានបិតព្រះខ័ន្ធ សោកណាថ្លៃថ្លា មានឫទ្ធិអស្ចារ្យ សម្លាប់យក្ខបាន ។ កាលនោះពុំលង់ ពោធិ៍សត្វទ្រង់ យកខន្ធថ្វាថ្កាន លីលាយាងទៅ ដល់ប្រាសាទស្ថាន បង្គំក្សត្រក្សាន្ត ព្រះវរបិតា ។ ព្រះបាទព្រហ្មទត្ត ទតយល់រាជបុត្រ មកដល់ហើយណា ទ្រង់ត្រាស់ប្រើវៃជ័យសុរិន្ទ្រា បូររាជបុត្រា អូសខ្មោចយក្សហោង ។ ពន្ធ្យពោធិ៍ណា ទទួលទុក្ខា ពិតពុំបង្អង់ ចេញចរម្នីម្នា លីលាតម្រង់ ដល់យក្សពុំលង់ ដែលស្លាប់នោះណា ។ ពោធិ៍ដល់ហើយ ពិតពុំលង់ឡើយ យកព្រះខន្ធថ្វា ដាក់ត្រង់ដើមទ្រូង នៃខ្មោចយក្សា ក្រវាត់ចោលពី ដល់ហោមតាទ្គ

ហោង ៗ ពស្រ្តទឹងមន្ត្រី ខ្លាចបុទ្ធបារមី កុមារច្បាស់ច្បង
ពុំបង្អង់នៅ វិលវិញជាមួង ចូលគាល់ច្បាស់ច្បង បង្គំពី
ក្សត្រ ៗ ឯព្រះបិតា មាតានោះណា ទតយល់បុត្រវង្ស
ដល់បង្គំហើយ បើកបន្ទូលថ្កាត់ សួរបុត្រកំសត់ ពន្ទុក
សង្ក្រាវ ៗ អ្នកអួសខ្មោចយក្ស ទៅបោលដៀងជាក់
ទីក្ដានឯណា តើឆ្ងាយប្ដិត ពោធិ៍ឆ្លើយថា ឆ្ងាយ
ណាស់បិតា សូមទ្រង់ជ្រាបហោង ៗ រីព្រះបិតា ទ្រង់
ជ្រាបហើយណា ត្រេកអរកន្ទង់ ហើយក្សត្រត្រាស់ប្រាប់
អ.ប់សេនាផង បានសុខហើយហោង ដោយបារមីណា ៗ
ឯពោធិសត្វ គង់គាល់ពីក្សត្រ បិតាមាតា បន្ទិចបង្គំ
លាទៅប្រាង្គប្រា សាទសេយ្យនា គង់សុខឥតហ្មង ៗ
ឯអស់មន្ត្រី ប្រជាពស្ត្រៃ សែនសុខកន្ទង់ ដោយបុណ្យបារមី
ក្សត្រថ្លៃច្បាស់ច្បង ឥតអំពល់ហោង ដោយហេតុអ្វីឡើយ ៗ
រីឯខ្មោចយក្ខ ដូជាតិអប្យណ៍ ធ្លាក់ដល់ហោមពាន្ត ឮលាន់
សន្ធឹក ផ្អើលមហាផង ទាំងនាគពងហោង ភ័យរត់ឆ្ងាយសល់ ៗ

ទៅទីនាៗ សត្វជនអាត្មា កម្រើកទៅដល់ ខែត្រខណ្ឌនគរ
អាសុរីសុកល សោយពជេច្កីនពល នៃកំពន្ធយក្ស ៗ
កំពង់ទិទ្រា ព្ទស្សូរដូចជា គេផាស់កន្ត្រាក់ ស្ដេចយក្ស
ភ្ញាក់ឡើង ធ្លល់មនុស្សក្រុយយក្ស កក្រើកឥតអាក់ ប្ដូព្រះ
អាចារ្យ ៗ ស្ដេចមកប្រពាទ ព្រៃហើយនរនាថ ចុះ
ស្រង់ផលសា ទើបពួសន្ទឹក មកដល់អញណា បើ
ដូច្នេះពី គួរយាត្រាទៅ ៗ យក្សគិតហើយហោង
ឈោងយកដម្បង ហោះទៅស្ទង់ស្ទៅ ដល់ឆ្នេរផលសា រក
ឥស្សរក្សូវ ពុំឃើញចមហៅ ស្ដេចយាតមកនៃ ៗ យក្ស
រឹងគន់គ្រប់ កន្ទផលសាសត្វ ឃើញខ្មោចយក្សស្រី មាន
ស្នាមដើមទ្រូង យក្សធ្លល់ពេកក្រៃ ៖ហើយគិតថាអញ
យកខ្មោចនេះនៃ ឲ្យអាចារ្យខ្ញុំ ស្ដេចប្រោសប្រាណហោង ៗ
ឲ្យរស់វិញណា ទឹងបានបវរា ស្លាកស្នួរដើមទង់ បើ
ព្រះអាចារ្យ ប្រាស់នាងហើយហោង រូបល្អឥតហ្មង យក
ធ្វើភរិយា ៗ យក្សគិតឡោះហើយ ពិតពុំលង់ឡើយ ត្រកងម្នា

យកខ្មោចនោះនៃ ហោះដោយវិហាស៍ ទៅបានដល់នា ឋាន
កៃឡាសហោង ៗ សន្សឹមថ្នមដាក់ មិនឲ្យថ្នឹងថ្នាក់ មន្ទិល
សៅហ្មង ទុកខ្មោចយក្ខនោះ នៅក្រៅកំងហោង ចូល
គាល់ច្បាស់ច្បង់ បង្គំទូលថា ៗ បពិត្រព្រះគុណ ពី
សេសមហាធ្ងន់ ដ្បិតខ្ញុំករុណា កែសខ្មោចយក្សស្រី
ពីក្នុងផលសារ មកថ្វាយមេត្តា ទ្រង់ប្រោសប្រោប់
ហោង ៗ ដ្បិតខ្ញុំនេះណា មានចិត្តសង្កា សង្ស័យជាម្តង
នឹងស្នាមដើមទ្រូង ប្រស់ឲ្យរស់ហោង បានដូចបំណង
ត្រេកអរណាស់សា ៗ កាលនោះព្រះបាទ ឥសូរនរនាថ
ស្តាប់សព្វកិច្ចការ ពិតពុំលង់ឡើយ ស្តេចយាងយាត្រា
ដល់ខ្មោចយក្សា សាកសពនោះនៃ ៗ រីកាលនោះណា
នាងនាថយក្សា បានរស់ឡើងថ្មី លើកករប្រណម្យ បង្គំ
នរបតី ក្រួញក្រាបសេរសើ អង្គុយនិត្យនៅ ៗ ទើប
ព្រះអាចារ្យ ស្តេចមានទុក្ខា សារស័ព្ទសួរទៅ អើសម្មី
អញឲ្យនាងនៅ ចាំស្រះម្តេចក្លូវ ក៏បានជាស្លាប់ ៗ ទើប

នាងសម្ទី ក្រាបទូលព្រះឥស្សរលើលោកា ថាកាល ព្រះអង្គឲ្យចាំស្រះណា គឺកម្មរាស្ត្រ ជាពៀរវេរ ។ មានក្សត្រ នរនាថ នាមឈ្មោះព្រះបាទ ព្រហ្មទត្តរាជា នាំអស់ពួកពល សកលយោធា ទាំងអគ្គជាយា មកប្រពាឲ្យស្រះ ។ ខ្ញុំម្ចាស់បានយល់ អង្គក្សត្រទសពល ឆោមឆើតល្អណាស់ ទប់ចិត្តមិនបាន ហេតុប្រាណកម្មក្រាស ចិត្តស្រឡាញ់ណាស់ ក្នុងកាយខ្វាយខ្វល់ ។ ចង់បានក្សត្រា ជាប្តីហើយណា ចាប់នាងនិម្មល ក្រវែងចោលទៅ ខ្ញុំនិមិត្តទល់ តាំងនាងនិម្មល ជាអគ្គមហេសី ។ ទើបព្រះរាជា នាំខ្ញុំលេលា ក្រុងពារាណសី ប្រាំពីរថ្ងៃបាន ដឹងហើយក្សត្រថ្វី ថាខ្ញុំយក្ខិនី សម្លាប់ខ្ញុំណា ។ រីឯនាងសម្ទី នាងទូលព្រះឥស្សរសព្វប្រការ ដូចបាននិទានពីមុនមកណា សព្វគ្រប់ប្រការ គ្មានខ្វះឡើយហោង ។ កាលនោះព្រះបាទ ឥស្សរនរនាថ បានស្តាប់សូរសៀងនៃនាងសម្ទី ទូលសព្វគ្រប់ហោង ទើបក្សត្របញ្ចាស់បញ្ចៀន

បន្ទូលត្រាស់ថា ៗ នៃនាងសម្ភី ឥឡូវនេះនែ កំព័ណ្ណានោះ
ណា ស្រង់នាងយកមក ពីក្នុងផលសា មកឲ្យអញពី
ប្រុសនាងឯងនែ ៗ ឥឡូវនេះណា បើដោយអញថា
គួរគាប់ប្រពៃ ត្រូវអញឲ្យទៅ កំព័ណ្ណានោះនែ យក
នាងវិលវៃ ទៅត្រង់ភាព ៗ គេមានគុណធ្ងន់ នឹងនាង
ណាស់លន់ ផ្សំពង្សនឹងគ្នា ឯនាងសម្ភី ស្រីស្រស់
ពុំងារ មានចិត្តចង់ជា នឹងស្តេចយក្ស ៗ ឯក្រុងកំព័ណ្ណ
មានចិត្តគួបគាន់ ប៉ុនប៉ង់ប្រាថ្នា លុះឮព្រះឥ- ស្វរ
បន្ទូលថា ផ្សំនឹងគ្នា ត្រេកអរកន្ទង់ ៗ ក្រាប
ថ្វាយបង្គំ លើកដៃប្រណម្យ ក្សត្រថ្ងៃច្បាស់ច្បង
ត្រេកអរណាស់សា ព្រមគ្នាជាម្តង ផ្សំស្រេចឥតហ្មង
យានប្តានដំណាក់ ៗ ឯនាងសម្ភី នឹងកំព័ណ្ណានៃ
វិហារក្សត្រទ្រង់សក្តិ ដល់ដំណាក់ហើយ អង្គព្រះទ្រង់
លក្ខណ៍ គង់លើអាសនៈ នៃនសុវណ្ណា ៗ ឯនាង
សម្ភី នឹងកំព័ណ្ណានៃ ប្រតិបត្តិអាចារ្យ និត្យនៅចាំ

ទ្រាំ បានបីថ្ងៃណា ឯអគ្គយក្ស កំព័ណ្ណនោះនៃ ។ គិតក្នុង ចិត្តថា ខ្លួនអញនេះណា ត្រឡប់វិលវៃ ទៅទៅទីឋាន អញឯនាយនៃ នាំនាងសម្ពី ទៅជាភរិយា ។ កំព័ណ្ណគិត ហើយ ពិតពុំលង់ឡើយ ចូលទៅម្ចា គាល់ព្រះឥសូរ បង្គំទូលណា សូមទាំងនាងនាថ សម្ពីផង ។ ឯព្រះឥសូរ មានព្រះបន្ទូល នាងទេណាហោង កំព័ណ្ណឯងទៅ រកយក្សជា បង នៅហេមវន្តហោង ឈ្មោះវិរុឡ្ហមេឃ ។ ឯស្តេច ក្រុងយក្ស បានស្តាប់ផ្តាក់ ទទួលឱកា នាំនាងសម្ពី នោះ នៃឯងណា លាព្រះអាចារ្យ នាំគ្នាទៅនៃ ។ ក្សិណ នោះរឹង នាងយក្សតែវៃ ទឹងកំព័ណ្ណនៃ នាំនាងហោះស្រូត ទៅស្នួរបងនៃ ក្រុងយក្សអសុរី វិរុឡ្ហមេឃណា ។ កំព័ណ្ណ ទៅដល់ វិរុឡ្ហមេឃយល់ កំព័ណ្ណអសុក នាំនាង សម្ពី ទៅដល់ហើយណា នោះក្រុងយក្ស អរក្រៃ កន្លង ។ ឯនាងសម្ពី បានដល់ហើយនៃ បង្គំរៀមបង ទើបវិរុឡ្ហមេឃ សាកសួរប្អូនហោង សព្វគ្រប់ជាម្តង

គ្មានសល់ឡើយណា ៗ ឯនាងសមុទ្ទ ទូលទៅ
បនិទ្ធី ប្រាប់សព្វហើយណា នាងទូលសព្វគ្រប់ ឥត
មានសល់ក៏ តាមដោយវាស្នា ពីមុនមកហោង ៗ ទើប
នាងសមុទ្ទី ទឹកកំព័ណ្ឌាវៃ លើកហត្ថទាំងសង ក្រាបទូល
សីរសី បង្គំលាបង ពុំយូរឡើយហោង ដល់នគរ ៗ
វិទិតនេះ សន្ធិបទុកសេះ បន្ទន់ចរចារ ទីនវិទិតនពី
ព្រះមហាក្សត្រា សោយរាជក្រុងមហា វង្កត់បុរី ៗ នាម
ឈ្មោះព្រះបាទ សូរីវង្សផាត មានស្នំសៅស្រី ប៉ែត
មុឺនសែនពាន់ មានអគ្គមហេសី ទ្រង់ព្រះនាមនៃ សូរ
ជាតបុប្ផា ៗ ជាធំចម្បង លើសអស់ស្នំផង ទាំងឡាយ
នោះណា ស្តេចមានរាជបុត្រ ស្រីល្អស្អាង ឈ្មោះសុវណ្ណ
បុប្ផាស្រស់ស្រី ៗ មានរិទ្ធិអំណាច សត្រូវខ្លបខ្លាច
លើសអស់ក្សត្រិយ៍ ស្តេចមួយរយមួយ នាំសួយមក
នៃ ចូលថ្វាយនរបតី គ្រប់ក្សត្រនោះហោង ៗ សឹង
ខ្លាចបារមី ព្រះបាទនរបតី ក្សត្រក្សាន្តជាប្បន ស្តេចគង់

ប្រាសាទ ប្រសើរកន្លង ដាំត្បូងច្រើនហោង ព្រោង
ព្រាយគួរស្ញែង ៗ អ្នកនគរ វង្កត់បវរ មានឈ្មួញ
តែង នាំអស់ទំនិញ ចូលចេញផ្សេងៗ លក់ទិញផ្សេង
ច្រើន បរិបូណ៌ណាស់នៃ ៗ និទានពីក្សេត្រ ស្តេចសោយ
សម្បត្តិ ទ្រង់ធម៌ប្រពៃ និទាននេះស្ទុះ បង្អង់សិននៃ
នឹងថ្លែងសេចក្តី ពីសេកវិញណា ៗ រីសេកនោះនៃ កូនក្នុង
រន្ធជ្រៃ លើក្នុបញ្ចូតា កែណាស់នោះនៃ មានថ្ងៃមួយណា
ព្យុះខ្លាំងអស្ចារ្យ ផាត់ជ្រៃនោះហោង ៗ កូនសេកនោះពីរ
មួយឈ្មោលមួយញី កិតក័យកន្ទង ខ្យល់គួចទៅផាត់
កូនសេកនោះហោង ព្រាត់គ្នាជាមុន ខ្ចាត់ទៅទីទៃ ៗ
កូនសេកតូចណាស់ មិនទាន់ដុះក្រាស មិនចេះហើរនៃ
ខ្យល់ផាត់ប៉ើងទៅ បែកគ្នាទីទៃ កូនសេកញីនៃ ដល់
វង្កត់ណា ៗ ធ្លាក់លើដំណាក់ ឆោមឆើតវលក្សណ៍
សុវណ្ណបុប្ផា នាងទតទៅយល់ ចាប់យកមកណា ចិញ្ចឹម
រក្សា លុះធំឡើងហោង ៗ សេកចេះស្រដី ពាក្យពេជ្ញ

អ្វីៗ បេះស្តីកន្ទង់ នាងសុវណ្ណា បុប្ផាសោភ័ណ បេះស្រ
ដីហោង រកនាងធីតា ៗ កូនសេកឈ្មោលនោះ ខ្យល់
ផាត់ធ្លាក់ចុះ ទៅដល់ព្រះមហា ព្រះឥសីវិញ កាល
នោះព្រះមហា តាបសអាចារ្យ ឥសីយល់ហើយ ៗ
លោកមានមេត្តា យកសេកនោះណា មកពុំលន់ឡើយ
ចិញ្ចឹមកូនសេក នោះបេះស្តីហើយ មិនឲ្យហ្មង់ឡើយ
ហើយឲ្យសេករៀន ៗ អាគមគាថា សិល្បប្រាសាទណា
ចំណេះរបៀន មន្តវិជ្ជាការ ឲ្យសេកសូត្ររៀន បេះ
សព្វរបៀន ឥតមានសល់អ្វី ៗ ឯរឿងនេះណា បន្ទន់
ចរចា កុំនិយាយស្តី នឹងនិទានណា ពីមហាក្សត្រថ្ងៃ
ព្រហ្មទត្តដៀស្ដដៃ ក្រុងការបុរី ៗ នៃបទឹងនាងនាថ
សុគន្ធថោងជាតិ ព្រះរាជមហេសី មានកាលថ្ងៃមួយ
ព្រះបាទនរបតី ទឹងនាងនាថនៃ ក្នុកព្រះចិន្តា ៗ
គាល់ព្រះឥសី នោះនាងនាថនៃ ទឹងព្រះកស្តា គង់
គិតទឹងប្រើ ដៃសូរីវង្សា ទៅសួរព្រះមហា ឥសីបាន

-១៣៣

ម្តង ៗ បែរបទបន្ទោលភ្លក់ កាលពន្ស្រេតាជបញ្ញាស់
ច្បង ថ្ងៃមួយនោះហោង អ្នកចូលទៅគាល់បិតា ៗ
រីឯព្រះបាទ ព្រហ្មទត្តនរនាថក្សត្រា យល់បុត្រហើយ
ណា មានព្រះឱង្ការទៅថ្កាន ៗ ថាជ័យសូរីវង្ស បុត្រ
ប្រុសមានទ្រង់កល្យាណ ឪពុកពុំក្សាន្ត គិតគានព្រះឥសីណា ៗ
ប្រើបារចរលី - លានឹងពាជ័យាត្រា ទៅសួរព្រះមហា ឥសី
អាចារ្យនោះហោង ៗ ពន្ស្រេតាជដ៏កូល ឮព្រះបន្ទូលសាសន៍
ទ្រង់ត្រាស់ប្រើហោង ទទួលព្រះរាជឱង្ការ ៗ តោជបង្គំ
ទសករប្រណម្យទូលថា ខ្ញុំទៅនេះណា យូរហើយទើប
វិលមកហោង ៗ ខ្ញុំចង់ទៅរៀន អស់ទាំងរបៀនសិល្ប
ផង លុះចេះអស់ហោង ទើបបានខ្ញុំវិលវិញណា ៗ ឯនាង
សុគន្ធ - មេចាងវត្តឧត្តមថ្ងៃថ្លា ឮបុត្រទូលថា ទៅយូរទើបបាន
មកហោង ៗ នាងលោមបុត្រថា កុំកែវមាតាសាសន៍ ថាដូច្នោះ
ហោង ទៅហើយឆាប់មកវិញណា ៗ សព្វថ្ងៃអ្នកនៅ ម្តាយ
បានយល់ពៅស្នេហា ទាំងពីរនាក់ណា ពុំដែលឃ្លាតទៅ

ណាឆ្ងាយ ៗ បើទៅដល់ហើយ ព្រះលឹង្គមាយអើយ ខ្វល់ខ្វាយ ទូលប្រាប់ថាម្តាយ ក្រាបថ្វាយបង្គំមកហោង ៗ រឺឯព្រះបាទ ព្រហ្មទត្តនរនាថម្ចាស់ម្ចង បើកព្រះសាសន៍ បន្ទូលផ្តាំទីនបុត្រថា ៗ បើបាទទៅដល់ បានជួបយន់យល់លោកតា ចូលបាទូលថា អញនេះលើកករប្រណម្យ ៗ មកគាល់ព្រះគុណ វិសេសមហាធ្ងន់ឧត្តម មានចិត្តបារម្ភ គិតមកព្រះគុណ ណាស់ហោង ៗ ផ្តាំស្រេចព្រះបាទ ព្រះបរមនរនាថ ម្ចាស់ម្ចង ប្រើអាមាត្យហោង ឲ្យទៅប្រាប់រាជមនោម័យ ៗ អាមាត្យនោះណាទទួលឱង្ការហើយនៃ ចេញទៅធាប់វៃ ដើររដល់រោងរាជអសុតាហ៍ ៗ ប្រាប់ថាព្រះបាទ បរមនរនាថរាជា ហៅរាជអសុតាហ៍ ឲ្យទៅឥឡូវនេះហោង ៗ កាលនោះអសុតាហ៍ឮហៅ រាជាម្ចាស់ម្ចង ទ្រង់ត្រាស់ហៅហោង ចេញពីរោងទៅម្នីម្នា ៗ ស្តេចឲ្យយកគ្រឿង ប្រដាប់រុងរឿងសោភាមកស្អាងអសុតាហ៍ គ្រប់គ្រឿងប្រដាប់ហើយហោង ៗ កាល

នោះព្រះបាទ ក្សត្រក្រុទ្ធនាទោចប្រាស់ប្រេង ឲ្យបុត្រាហេង ទ្រង់គ្រឿងរុងរឿងថ្កាត់ ៗ ហើយយាងបាទា ផែលឡើង អសុពាហ៍នោះថ្វាត់ ទាំងពីរពង្សក្សត្រ ចំរើនជន្ម័យបេស្តា ៗ កាលនោះពោធិ ទឹងភពតាជីនោះណា ហោះឡើង ទៅអា កាសហើយប្រទក្សិណបាន ៗ បីជុំហើយណា ទើបភពអាសាហោះប្តាន ត្រោះទៅត្រង់ឋាន ព្រះមហា ឥសីនោះហោង ៗ សេះហោះលឿនលន់ ខ្លាំងណាស់ ពេកពន់កន្លង ថ្ងៃទៀបត្រង់ហោង បានដល់ព្រៃហេមពាន្ត ណា ៗ ទើបពោធិសត្វ បន្ទូលត្រាស់ថ្វាត់សួរថា បងអើយបានមហា ឥសីជិតហើយឬនៅ ៗ ទើបភពអា សា ទូលស្នងខុន្តាវិញទៅ ថាឥសីនៅ ឆ្ងាយណាស់ នៅឡើយក្សត្រថ្ងៃ ៗ ពោធិសត្វណា ឮតាជីថាឆ្ងាយ ក្រៃក្រ សួរទៀតថាថ្ងៃ នេះយើងទៅដល់ឬទេ ៗ តាជី ទូលថា ដល់ព្រះសុរិយាជ្រៀងជ្រេ ខ្ញុំហោះឡើងឲ្យ កុំព្រួយព្រះរាជហឫទ័យ ៗ ពោធិវង្សត្រកូល ព្រះទ័យបង់

ចូលលេងព្រៃ ប្រាប់ទៅអាជទេយ្យ ថាយើងលេងព្រៃ
សិនណា ៗ រីកជតាជី ឮពង្សពោធិ៍ប្រាប់ថា ដូច្នោះ
ហើយណា ហោះចុះដល់ដីភ្លាមហោង ៗ ហើយកជ
តាជី នាំពង្សពោធិ៍ច្បាស់ច្បង់ មកព្រឹកព្រៃផង ស្រោង
ស្រាំងត្រៃឈើសាខា ៗ ពោធិ៍សត្វហោង គង់ស្និទ្ធលើខ្ទង់
អាស្ចារ្យ៍ មកសត្វនានា អស់ទាំងព្រឹក្សានោះហោង ៗ
លុះដល់សុរិយេ រសៀលជ្រៀងជ្រេកន្ទង់ ល្ងាចណាស់
ហើយហោង តាជីទូលពោធិ៍ថា ៗ បពិត្រអម្ចាស់ ថ្ងៃ
នេះល្ងាចណាស់ហើយណា ល្មមយើងយាត្រា ទៅបាន
ព្រះឥសីហោង ៗ ពោធិ៍វង្សកូល ស្តាប់តាជីទូលសាសង
ថាដូច្នោះហោង ទើបមានព្រះបន្ទូលថា ៗ រអញនេះ
ហោង អញតាមតែបងឯងណា បើល្មមយាត្រា គួរ
ការតែបងឯងនៃ ៗ ឯកជអាសារ ឮបន្ទូលថាឆាប់រៃ
ចរចេញពីព្រៃ លេចវាលស្មុះហោះដល់ស្ថាន ៗ ថ្ងៃនោះ
ណា ឥសីសិលាពុំបាន ទៅអាស្រមបាន លោកស្និទ្ធ

ស្វាធំជមិតាវិនា ៗ លោកឲ្យសេកនៅ ហើយបរទៅម្នម្នា

ផ្តាំឲ្យសេកថា នៅចាំតាស្រមនោះនៃ ៗ រីឯតាជី នាំ

ពន្សពោធិទៅវិ ទៅដល់ហើយនៃ ពុំយល់ឥសីឡើយ

ណា ៗ យល់ស្វាត់សូន្យឈឹង ពាដ៏រពឹងគិតថា នេះ

សមព្រះមហា ឥសីលោកទៅព្រៃហាន ៗ ទើបស្វាត់

ដូច្នេះ ហើយសេកសំណេះសាសន៍ ទូលពោធិហាន

ឲ្យឡើងគង់លើសាណា ៗ ឡើងទៅគង់ថ្កាត់ លើសាណា

វត្តហើយណា ឯសេកបក្សា ក្រឡេកមើលមកយន់យល់ ៗ

ឃើញពោធិសត្វ គង់ឯកអង្គក្យត្រែទសពល សេកមើល

មកយល់ តោមតែតលើសលៃនទេត្តា ៗ សេកហើរ

មកហាន ទុំហើយផ្សៀងផ្អងបរបា សួរពោធិថា អ្នកមក

បើមានឧរគក្ស ៗ ទើបពោធិសត្វ ប្រាប់ទៅសេកថ្កាត់

វិញថ្មី ថាមញ្ញនេះនៃ មកកេឥសីសិណា ៗ សេកព្

ព្រោះហើយ សេកសោកខ្លាស់ខ្លួយ ប្រាប់ថា ពុំនៅឡើយ

ណា លោកគាទិមន្តទៅព្រៃ ៗ ពោធិសួរថា

សេកអើយលោកតានោះនៃ និមន្តទៅព្រៃ ល្ងាចហើយ ពុំឃើញមន្តមក ៗ សេកស្តាប់ហើយហោង ទើប សេកសាសង់ប្រាប់ថា ថ្ងៃនេះណា លោកតាពុំបានមក ឡើយ ៗ គ្រប់ប្រាំពីរថ្ងៃ ទើបបានវិលវៃជាត្រើយ ថ្ងៃនេះ អ្នកកើយ លោកតាពុំមកឡើយណា ៗ អ្នកមកនេះ ហោង មានបើប៉ុនប៉ង់ប្រាថ្នា រកអ្វីលោកតា ប្រាប់មកឲ្យ បានដឹងផង ៗ ពោធីប្រាប់ថា អញមកនេះណាប៉ុនប៉ង់ មកនៅនេះហោង ហើយនឹងរៀនអស់គាថា ៗ អញនឹងយក វត្ត បង្គំប្រតិបត្តិលោកតា រៀនអស់គាថា រៀនសិល្ប សាស្ត្រនោះហោង ៗ សេកសោតស្មោះសរ មានចិត្ត ត្រេកអរកន្ទួង ថាស្តេចនៅផង គ្រាន់បានជាគ្នាហើយ ណា ៗ សេកឲ្យពោធី ស្តេចគង់នៅទីសាលា នឹងសេកនោះ ណា រុងចាំឥសីនោះហោង ៗ រីឯពាជី ណាពង្សពោធីនោះ ហោង ទៅស៊ីស្មៅផង ពោធីបើកតាមចិន្តា ៗ ពាជី លាហើយ ពិតពុំលង់ឡើយយាត្រា ចេញពីសាលា ទៅ

រកស្ដេចបរិភោគហោង ។ ឯព្រះឥសី ទៅបំពើនទ្វី
ធមិផង ប្រាំពីរថ្ងៃហោង វិលវិញមកឋានអាស្រម ។
មកដល់ហើយណា ឥសីសិលាឧត្តម ឡើងលើអាស្រម
ឥសីឈប់ឈរពេក ។ ពោធីយល់ហើយ ពិតពុំលង់
ឡើយម្ចីមា ចរចូលវន្ទា បង្គំព្រះឥសីណា ។ ពោធី
វង្សក្រូល ប្រណាម្យហើយទូលពន្ធដីកា ថាខ្ញុំករុណា
មកនេះពីការបូរី ។ ខ្ញុំបុត្រព្រះបាទ ព្រហ្មទត្តនរនាថ
នរបតី ព្រះមាតានៃ នាមនាងសុគន្ធថានីហោង ។ ជា
ចៅលោកតា ដោយដំណើរថានោះផង កើតកន្ផ្កាហោង
ខ្ញុំនេះជាបុត្រលោកនៃ ។ ព្រះវរមាតា នឹងព្រះបិតា
ជៀស្ឋៃជ ប្រទាននាមនៃ ខ្ញុំឈ្មោះសូរិវង្ស ។
ពីក្យត្រឧត្តម នោះយល់ខ្ញុំធំហើយណា ដល់ព្រួយចិន្តា
គិតមកលោកតាណាស់នៃ ។ ព្រះវរមាតា ព្រះវរ
បិតាជៀស្ឋៃជ រឹងព្រួយព្រះទ័យ គិតមកព្រះគុណណាស់
ហោង ។ ប្រើខ្ញុំករុណា នេះជះអាសារពោះផ្សង

មកដល់នេះហោង ក្រាបថ្វាយបង្គំលោកតា ។ ពីក្សត្រឧត្តម ក្រាបថ្វាយបង្គំមកណា សព្វថ្ងៃបិតា នឹងព្រះមាតានោះហោង ។ ឯព្រះឥសី ស្តាប់ពាក្យនៃសាសន៍ ទ្រង់ជ្រាបហើយហោង ថាកូនសុគន្ធថោងណា ។ ឥសីត្រេកអរ សោមស្សសាទរពេកណា មានពុទ្ធដីកាថា អើតាអរណាស់ចៅអើយ ។ អរនឹងកថា អរនឹងនាងនានោះហើយ ឥឡូវចៅអើយ ថាទេព្ទមានអ្វីណា ។ ពោធិវង្សទូល ប្រណមក្រាបទូលទៀតថា បពិត្រលោកតា មាតាកើតទុក្ខក្តាត់ហោង ។ មានថ្ងៃមួយណា ព្រះវរបិតាបញ្ជាស់បញ្ជូន នាំមាតាហោង ចេញប្រពាស់ព្រៃព្រឹក្សា ។ មានយក្ខិនី មួយនោះគ្មានប្តីឡើយណា ។ វាផ្សាបមាតាវក់ឆ្គួតដូចសត្វពោចហោង ។ ហើយយក្ខនោះណា វាប្រែកាយារូបស្ងួន ដូចមាតាហោង បិតាពុំដឹងឡើយណា ។ ខ្ញុំនេះមើលយល់ ឃើញយក្ខកំហាលមោហា ចាប់ចោលមាតាហើយប្រែកាយាចាប់វៃ ។ ឯព្រះមាតា កាលមេយក្សា

ពោលនៃ អ្នកស្ទុះឡើងវ៉ៃ ដើរទៅលើខ្នេរផលសា ៗ
ស្រែកហៅខ្ញុំហោង អស់ពាំងមនុស្សផងគេថា ជាទោបទេ
ណា ពុំស្គាល់ជាមាតាឡើយ ៗ តែខ្ញុំនេះហោង នឹង
អនុជផងស្គាល់ហើយ ពិតពុំលង់ឡើយ រត់តាមមាតា
ជាម្ដង ៗ ឯព្រះបិតា ខ្វល់នឹងខ្ញុំណាកន្លង ចេញ
ទីនាំងហោង ហើយស្ដេចនាំនាងយក្ស ៗ ទៅ
រួមបន្ទំ ព្រាំពីរថ្ងៃខ្ញុំយាត្រា ទៅកាប់យក្ស យក
ឈាមលាបមាតាហោង ៗ បានជាហើយណា ទើប
ព្រះបិតាច្បាស់ច្បង នាំមាតាហោង ទៅគង់ដូចដើម
វិញណា ៗ មុនីវត្តឥសី ទ្រង់ជ្រាបហើយនែអ្នកថា
អើអញនេះណា តែងនឹកគិតទៅដែរហោង ៗ ឥឡូវចៅ
មក ជជ្រុលជជ្រកកន្លង មកដល់តាហោង អ្នក
កុំគាលទៅឡើយណា ៗ ចាំតាបង្រៀន សិល្បៈ
សាស្ត្ររៀនគាថា ចេះអស់ហើយណា សឹមចៅ
វិលទៅវិញហោង ៗ កាលនោះពោធិ លើកគអញ្ជលីទូល

ស្អួន ថាខ្ញុំអរហោង ចង់រៀនឲ្យអស់ចិត្តណា ៗ
ទើបព្រះឥសី ឲ្យពង្សពោធិ៍ថ្ងៃថ្វា គន់នៅសាលា
ហើយព្រះឥសីនោះហោង ៗ សង្វាតបង្រៀន អស់ទាំង
របៀនសិល្បផង ប្រាំពីរថ្ងៃហោង ចេះចប់ឥតឯខ្វះឡើយ ៗ
រៀនចប់រៀនប្រស់ រៀនទាំងឈានហោះបានហើយ ឥតឯ
ខ្វះឡើយ រៀនប្រែកាឡានោះណា ៗ ឥសីបុទ្ធិ ប្រិត
ប្រៀនពោធិ៍ថ្ងៃថ្វា ប្រៀនសិល្បធ្នូណា នោះអ្នកចេះស្ទាត់
ហើយហោង ៗ ឥសីបវរ ចប់ធ្នូចប់សរឲ្យផង តែព្រះ
ខាន់ហោង ឥសីពុំបានចប់ឡើយ ៗ ដ្បិតមានព្រះខាន់
ជ័យជាកំណាន់ស្រេចហើយ ហេតុដូច្នេះហើយ ចប់តែ
ធ្នូសរឲ្យហោង ៗ ហើយព្រះឥសី យកធ្នូសរជ័យឲ្យផង
ឲ្យពោធិ៍ហោង នោះអ្នកទទួលយកណា ៗ ហើយអ្នក
បង្គំ ក្រញួក្រាបប្រណម្យព្រះមហា ឥសីសិលា ប្រ-
សិទ្ធីមន្តជោគជ័យ ៗ មន្តមួយឲ្យឈ្មោះ អស់អសុរ
ពាលតិរ្ថៃ មន្តមួយជោគជ័យ កុំឲ្យអសុរនោះណា ៗ

ទោះស្ដេចយកក្រុឌ តាពុះប្រយុទ្ធម្ដេចម្ដា ឲ្យចាញ់
បេស្ដា ខូចខ្វាចអំណាចចៅហោង ៗ ហើយ
ព្រះឥសី ចម្រើនអស់ន័យពរផង ស្រាប់ស្រេចហើយ
ហោង វិលថ្កានកស្រមវិញណា ៗ ពោធិសត្វថ្ងៃ
ស្ដេចគង់នៅនៃសាលា សព្វថ្ងៃនោះណា តែងពោប្រតិបត្តិ
ឥសី ៗ រីឯនិទាន តមកនេះមានសេចក្ដី តាំងពី
ចក្រី ព្រះបាទព្រហ្មទត្តនោះណា ៗ ស្ដេចផ្សងព្រះ
ខាន់ ហើយក្សត្រសោកណ៍ថ្ងៃថ្វា តនឹងយក្ស រៀន
មកដល់ពោធិសត្វ ៗ មកដល់ព្រះមហា ឥសីសិលា
នោះថ្វាត់ ដល់ពោធិសត្វ ទ្រង់រៀនសិល្បចប់ហើយណា ៗ

បទកាកនេះនី ទានតអំពី អគ្គីពជក្សត្រា កាលពោធិសត្វ
គង់នៅសាលា សព្វថ្ងៃនោះណា បំរើឥសី ៗ មាន
កាលមួយថ្ងៃ ពោធិសត្វថ្ងៃ បបួលសេកថា សេក
កើយយើងទៅ លេងព្រៃម្ដងណា រកបេះផលា ថ្វាយ
លោកតាពោង ៗ សេកសោតឆ្លើយថា បើស្ដេច

ទៅណា ខ្ញុំបន់ទៅផង បើស្ដេចយាងទៅ ខ្ញុំទៅដែរហោង នាំគ្នាត្រសង ជាពីរនាក់ហើយ ៗ ទើបពោធិសត្វ បបួលទៀតថ្លាត់ ថាអើសេកអើយ បើថាសេកទៅ កុំនៅយូរឡើយ មកទៅសេកកើយ ទៅលាលោកតា ៗ សេកសោតបានស្ដាប់ អស់គាថិសាស័ព្ទ ពោធិសត្វថា ឲ្យទៅឲ្យឆាប់ ជាប្រញាប់ណា ទៅលាលោកតា ទឹងទៅលេងព្រៃ ៗ សេកលោតត្រូសពន់ ស្មើទាន់ពុំទាន់ ម្នីម្នាឆាប់ខ្លី សេកហើទៅថ្កាន អាស្រមហើយនៃ ពោធិយានវៃ ទៅដល់ហើយណា ៗ បត់បាទបង្គំ ទសករប្រណម្យ ទើបទូលទៅថា ខ្ញុំសូមប្រណិបត្តន៍ ទឹងលាលោកតា ទៅលេងព្រឹក្សា ទឹងសេកនេះហោង ៗ ឯព្រះឥសី ព្រះពោធិនៃ ទឹងសេកនោះផង លាទៅលេងព្រៃ ដូច្នោះហើយហោង ឥសីសារសេង ប្រាប់ពោធិថា ៗ នៃជ័យសុរិន្ទ្រ ចិត្តបាទនឹកចង់ ទៅលេងឯណា អ្នកទៅតាមចិត្ត កុំគិតក្រែងថា ខ្លាចគ្នី ៗ

ណា អ្នកកុំគិតឡើយ ៗ ពោធិសត្វថ្លៃ ឮព្រះឥសី
បើកឲ្យទៅហើយ សេកទទឹងពោធិ៍ ពិតពុំលង់ឡើយ
បង្គំលាហើយ រំលងស្ថានសាលា ៗ ដល់ហើយនរទេះ
និម្មិតកាយច្បាស់ ជាសេកហើយណា សេកសោកបាន
យល់ ពោធិ៍តាឡ្វា កើតជាសេកណា អវគ្រៃកន្ទង ៗ
ហើយបបួលគ្នា នាំចរលេលា ហើរទៅត្រសង ដោយ
កៀនដោយគោះ ឥតបន្ទោះហោង ហើរហ្លួសរំលង ទៅដល់
ស្រះស្រង់ ៗ នុទ្យានព្រះបាទ សូរិន្ទ្រជាតិ សម្រាប់ព្រះ
អង្គ រៃគន់មកក្រសាល ប្រពាឲ្យស្រះស្រង់ កំសាន្តព្រះអង្គ
វៀនពបមកណា ៗ សេកហើរទៅដល់ រមិលមើលយល់
អស់ទាំងផលា ក្នុងស្រះនោះហោង មានទាំងព្រឹក្សា ហើយ
មានផលា ខ្ទុំធំនោះហោង ៗ សេកពោធិ៍យល់ ក្រុះ
ជាតិគល់ នាំគ្នាស៊ីហោង អស់ទាំងផលា ស្កប់ស្កល់ជា
មង្គល ក្នុងថ្ងៃនោះហោង សុវណ្ណបុប្ផា ៗ រូបរ័ក្ខនល្អង
នាំសៅឡើកផង ឡើងលាបិតា នូនកាយប្រណម្យ បង្គំ

ទូលថា ទៅលេងព្រឹក្សា ឧទ្យានស្រះស្រង់ កាលនោះ ព្រះបាទ សុរិវង្សជាតិ យល់បុត្រនោមយន់ ៗ បង្គំលាទៅ លេងឯស្រះស្រង់ បើកតាមចិត្តចង់ ពុំឃាំងឃាត់ឡើយៗ នាងនាថសុវណ្ណ បុប្ផាសោភ័ណ បិតាបើកឱ្យ នាងថ្វាយ បង្គំ លាពុំលង់ឡើយ នាងវិលវិញហើយ ដល់ប្រាសាទពៅ ៗ នាងទ្រង់ភ័ត្រខៅ កញ្ចៀលកងកែវ កងកន់ហត្ថា សង្វា ពន្ធព័ទ្ធ ទ្រង់ស្បៃកាសា ដេតឆាយអស្ចារ្យ រូបពង សមប្រាណ ៗ នាងទ្រង់ព្រះភ័ស្ត្រ ប្រពៃស្រេចស្រស់ អស់អង្គកល្យាណ ដូចទេពអប្សរ បរចុះចាកឋាន តុះសិក មកឋាន ផែនដីនេះហោង ៗ នាងនាថធីតា ស្អាងអង្គ កាយា ស្រាប់ស្រេចឥតហ្មង ហើយនាងយកសេក ទៅ ជាមួយផង នឹងសៅឡុកហោង ចេញចាកពិន័យ ៗ បានដល់ផ្លូវ នាងនាថធីតា ទៀងគង់រថទៃ មន្ត្រីសេនា រៀបហែនាងខ្ញុំ ពួកពលសេនីយ៍ ហែរទៅហើយណា ៗ សេកល្អនោមនាយ ពុំដែលឃ្លាតឆ្ងាយ នាងនាថឡើយ

ណា ឯអស់មន្ត្រី សេនីសេណា ប្រុងប្រយ័ត្នការណ៍ ហែនាង ទៅហោង ៗ លុះបានដល់ព្រៃ មានម្លប់ទ្រៃឈ ខ្ពស់ស្រោង កន្ទួង នាងទតបក្សី មកព្រានោះហោង ទុំបិកភ័ស្តុផង សូរស័ព្ទយំ សារិន ៗ នាងនាថទតយល់ វុក្ខជាតផល ផ្លែផ្កាយោនយាន តាមផ្លាយមាគ៌ា ផ្លែផ្កាមែនមាន ក្នុងព្រៃហេមពាន្ត ក្បែរ ឆ្នេរស្រះហោង ៗ ពលច្រើនណាស់ណា កកកុញគ្រៀម គ្រា នាងនាថទង់វង់ ទឹងសៅឡឹកណា ដល់ស្រះ ជាមួង ដាក់ពងរថហោង ឲ្យសង់ពន្លា ៗ សេនាមន្ត្រី ទទួលសុវណ្ណី រៀបឆ្មើមឆ្មា រូបស្រួចហើយហៃ ទើប នាងតុំងារ សុវណ្ណបុប្ផា នាំគ្នាស៊ើបសារិន ៗ ឮដល់ ពោធី ស្តេចទតមកទី ឆ្នេរស្រះយល់មាន ពលពាស ការសារ សេនាទាហាន ទតមើលវិមាន តាំងព្រះ ពន្លា ៗ យល់តាំងក្បត្រី ឆោមឆើតពីសី ពីសេសសោ ភា យល់អស់សៅស្រី ជាកងបរិពារ យល់តាំង សេកកៅ ទុំទៀបនាងហោង ៗ ពោធីគិតថា រីនាងនោះ

ណា ល្អល្អះក្នុង ទឹករគអស់ស្រី ដៃទង្គឹមផង ទឹក
នាងនោះហោង កុំបានឡើយណា ៗ នាងសព្វព្រះទ័យ
ទឹងនាងណាស់នៃ ឥតឧបមា ហើយស្ដេចសួរសេក ត្រេក
ត្រាស់បរថា កូនស្ដេចស្រុកណា សេកស្គាល់ឬទេ ៗ
ក្រែងសេកហើរទៅ តើបានទាំងនៅ នគរមាសមេ សេក
ឯងបានស្គាល់ នៃនាងឬទេ ស្រុកទេសមាសមេ នៅឯ
ណាអើយ ៗ សេកទូលវិញថា បពិត្រព្រះមហា ក្សត្រា
ត្រាណាតើណា ខ្ញុំម្ចាស់នេះណា ពិតពុំស្គាល់ឡើយ នាង
នេះម្ចាស់អើយ ល្អអ៊ីម៉្លេះណា ៗ វង់ភ័ក្ត្រត្រយង់ ថ្ងាជ្រះផូរផង់
ដូចទេពកញ្ញា នាងនេះជាបុត្រ ស្ដេចនៅស្រុកណា បើបាន
ក្សត្រា សមគ្នាណាស់ហោង ៗ ទើបពោធិសត្វ
សួរទៅសេក ថ្នាក់ សំណោះសារសង ជាអញ្ញសមហើយ
ទឹងនាងឥតហ្មង សេកញីនោះផង សមទឹងសេកឯង ៗ
សេកឆ្លើយ វិញថា បពិត្រក្សត្រា ជាម្ចាស់តម្កើង
សមទឹងខ្ញុំហើយ ធ្វើម៉េចទឹងស្នូង បាននាងនោះឯង

ពុំយល់គ្នាណា ៗ ទើបពោធិសត្វ បន្ទូលទៀតថ្វាត់ ទៅ
នឹងសេកថា បើច្នះយើងទៅ កុំនៅនេះណា កុំឲ្យធីតា
យល់យើងឡើយហោង ៗ នាំឲ្យធីតា ទៅលើព្រឹក្សា បេះ
អស់ផលធំ សីមាសេកឯងទៅ បង់បានដូចប៉ង បានហើយ
ច្បាស់ច្បង់ ប្រើសេកនោះណា ៗ សេកហើរទៅដល់ ព្រៃ
មួយធំសល់ ត្រសុំសាខា លបពួនសំណាក់ លាក់អង្គអាត្មា
ទិត្យនៅនោះណា ចាំមើលនាងហោង ៗ ហើយពោធិសត្វ
ប្រែនិម្មិតថ្វាត់ ជាក្សត្រច្បាស់ច្បង់ ដោមដេតទ្រង់ស័ក្តិ វង់
ក័ក្រ្កឥតហ្មង ដូចឥន្ទ្រាហោង ចុះមកផែនដី ៗ សេកយល់
ពោធី ប្រែខ្លាយអង្គពីរ សេកនោះឯងនែ ជាអង្គមហាក្សត្រ
ដូចជាប្រក្រតី ទ្រង់ដោមពីសី លើសទិព្វសួគ៌ា ៗ សេកទូល
ថាខ្ញុំ យល់នាងស័ក្តិសម នឹងព្រះកយ៉ា ល្អណាស់អស់អង្គ
ត្រយង់ដូចគ្នា ស័ក្តិសមគួរជា ព្រះទេពីហោង ៗ ស្តេចស្តាប់
ដំណើរ សាសព្ទសរសើរ ជាសមណាស់ហោង ស្តេចទ្រង់
ត្រេកអរ នឹងសេកកន្ទង់ ពោធិច្បាស់ច្បង់ បន្ទូលត្រាស់ថា ៗ

បើឈ្មោះសេកខំ គិតការរៀបចំ ចង់ឲ្យខ្ញុំណា បើបានគ្នា ហើយ ឯអញមិនថា គង់តែជីតា ទឹងបានអញហោង ៗ សេក សោតបានស្តាប់ អស់អាថ៌សាស័ព្ទ ក្សត្រថ្ងៃសាសង ថាឲ្យ សេកចង់ ឲ្យបានគ្នាហោង សឹមក្សត្របួងសួង បាននាង ក្រោយនៃ ៗ សេកឆ្លងឆ្លើយឆ្លាស់ ថាបើឈ្មោះម្ចាស់ កុំព្រួយ ព្រះទ័យ បើខ្ញុំបានគ្នា ធានាជួយលៃ ជួយព្រះជៀស្ឋ ជ័យ ឲ្យបាននាងណា ៗ ពោធិសត្វស្តាប់ អស់អាថ៌សាស័ព្ទ សាសង់វាចា សេកសោតធានា ទឹងជួយក្សត្រា ឲ្យបាន ជីតា ជាគូរួមប្រាន ៗ ថ្លែងពីសេកញី ស្វែងចំណីស៊ី ឆ្ងាយ ពីនាងហោង សេកហើរេក គ្រប់ដើមឈើផង រេករៀងទៅ ហោង ទៀបដល់ដើមជ្រៃ ៗ ឯពោធិសត្វ ស្តេចចេតទៅថ្វាត់ យល់សេកញីនៃ មកដូចឈ្មោះណា ទើបព្រះជៀស្ឋជៃ ប្រើ សេកចាប់វៃ ឲ្យទៅចង់ហោង ៗ សេកឮហើយណា អរ ក្នុងចិន្តា ពេកពន់កន្លង ឈាពោធិសត្វ ហើយហើរទៅ ហោង ដល់ហើយសាសង់ សួរសេកញីថា ៗ ប្អូន

មាសឧត្តម រាងរូបសក្តិសម មុខមាត់ជ្រះថ្លា ពៅនៅ
ព្រៃនេះ ប្តីកែវស្នេហា មាសមកពីណា ឃើញតែម្នាក់ឯងៗ
សេកញីញានស្តាប់ អស់អាប់សាស័ព្ទ សេកឈ្មោលថ្វា
ថ្វីង ដណ្តឹងសួរថា ឃើញតែម្នាក់ឯង សេកញីចាត់
ថែង ឆ្លើយប្រាប់ទៅថា ៗ ប្អូននេះនៃ ពុំមែននៅព្រៃ
នេះឯងឡើយណា ប្អូនមកអំពី វត្តរង្គា មកលេង
ព្រឹក្សា នៃម្ចាស់ក្សត្រី ៗ សុវណ្ណបុប្ផា ជាម្ចាស់ខ្ញុំណា
មានទាំងមន្ត្រី សេនាយោធា ហែរាជក្សត្រី មកប្រពាសព្រៃ
ឧទ្យាននេះហោង ៗ អ្នកឯងណា នៅក្នុងព្រឹក្សា នេះ
ឬអ្នកបង ឬមកពីណា ចរចាប្រាប់ផង ឲ្យប្អូននេះ
ហោង ដឹងដំណើរអ្នក ៗ សេកឈ្មោលឆ្លើយថា ឱប្អូន
ស្នេហា ខ្ញុំមខ្លួនវិលក្ខណ៍ បងនេះជាសៅ ព្រះឥសីដាក់
ចិញ្ចឹមថែរ - ក្រាបងនេះហោង ៗ លុះធំហើយណា នោះ
មានក្សត្រា ធិរាជច្បាស់ច្បង ឈ្មោះជ័យសុរិន្ទ្រ ទ្រង់
បុទ្ធិកន្ទង ជិះសេះហោះផ្សង មកពីភារា ៗ ក្រុងកាប៊ូរី

ព្រះបាទចក្រី មកបិតទៅនា ទីព្រះឥសី នោះនៃពជា

ចូលវន្ទា ថ្វាយខ្លួនជាចៅ ៗ ឥសីសិលា ទ្រង់ព្រះមេត្តា

ប្រិតប្រៀនប្រដៅ ទ្រង់ព្រះករុណា មេត្តាជ្រួតចៅ ប្រិត

ប្រៀនប្រដៅ បេះឥតខ្វះឡើយ ៗ ព្រះបាទក្សត្រា

នៅបំរើមហា ឥសីយូរហើយ មានកាលមួយថ្ងៃ នោះនៃ

ប្អូនអើយ ក្សត្រាត្រាណត្រើយ ភ្ញកព្រះហឫទ័យ ៗ

ចង់បានទេពី ហើយព្រះភូមី បបួលបងនៃ ទៅលា

ព្រះមុនី ឥសីឆាប់វៃ ព្រះឥសីនៃ បើកតាមចិត្តា ៗ

ទើបស្ដេចនាំបង ហោះមកនេះហោង រកពធីតា ស្រស់

ស្រីពន្លក រកដូចក្សត្រា ក្រែងមានសេកណា គាប់ទឹង

ចិត្តបង ៗ ឥឡូវមកជួន ជួបទឹងមាសស្ងួន មិត្រមេ

ស្នេហ៍ស្នង សមហេតុបុព្វ ពីព្រេងនាយហោង បុណ្យ

ជួយនាំបង មកជួបប្អូនស្រីៗ ស្រស់ស្រីឧត្តម រាងរូប

ស័ក្តិសម មុខមាត់ប្រិមប្រិយ បងសូមផ្ញើខ្លួន លើស្ងួនកុំបី

ផាះសាសេចក្តី ថាក្ដីប្អូនអើយ ៗ

បែរបទព្រហ្មគីត សេកថាមិត្រមាសបងអើយ ប្អូនមិនថាអ្វីឡើយ ព្រេងយើងហើយមកជួបគ្នា ៗ សេកញីមានចិត្តត្រេក បានស្ដាប់សេកឈ្មោលពណ៌នា ដំណើពីកជាស្ដេចមករកពជទេពី ៗ សេកញីចង់ស្នេហ៍ស្និទ្ធ ណាស់កន្ទីចិត្តឥតគណនា ហើយកែប្រែមាយា ធ្វើហាក់ជាពុំស្នេហ៍ស្និទ្ធ ៗ ថាយើអើសេកនេះ ហ៊ានអីម្ល៉េះទេណាហោង គេទាន់ជាអ្វីផង ហ៊ានថាធ្វើខុសលើគេ ៗ ពុំទាន់បានដឹងចិត្ត ដឹងគំនិតគេនោះទេ ថាធ្វើខុសលើគេ គេទាន់ទៅជាអ្វីហោង ៗ សេកឈ្មោលក៏ឆ្លើយថា ប្អូនស្នេហាព្រលឹងបង បានជាថាម្លោះហោង ដ្បិតបងមករកជួបស្រី ។ បានជាបងហ៊ានថា ធ្វើប្រាណណាលើប្អូនស្រី កែរកបណ្ដោមពីសើ សូមប្អូនស្រីអត់ទោសបង ៗ សេកញីធ្លាស់ឆ្លើយថា ហ្ន៎មើលក៏ប៉េះសារសង ឲ្យគេមេត្តាផងនោះតើមានបើហេតុអ្វី ៗ ប្អូនអើយបងនេះណា បានជាថាឲ្យប្រណី ដ្បិតបងប៉ងយកស្រី ស្រស់ប្រិមប្រិយជាភរិយា ៗ ពីកាលដើមថ្មោងថ្មី នោះមែនទែនចិត្តស្មោះស្ម័គ្រ ដល់យូរទៅ

ហើយអ្នក គេបដោះដៃពុំលែងឡើយ ៗ ឱប្អូនស្រស់បំណាច់ ស្ដាប់បងប្រាប់ណាស្ងួនអើយ បងនេះមិនហ្នោះឡើយ ទឹង ឧបមាឲ្យស្ដាប់ហោង ៗ ខ្លួនប្អូនដូចធរណី ផ្ញើជីវិតលើបង បីដូចដើមឈើផង ដុះនៅហ្នឹងក្នុងព្រឹក្សា ៗ ចិត្តប្អូននេះ សង្ស័យ ទឹងអ្នកថ្លៃក្រែងមោសា បញ្ឆោតលោមខ្ញុំណា បានហើយចោលទៅទៀតបាត់ ៗ ប្អូនអើយពាក្យបងទៀង ពុំឲ្យល្អៀងមានវិបត្តិ ស្ដីពាក្យសច្ចំពិត កុំព្រួយចិត្តព្រលឹង ណា ៗ សេកញីចូលចិត្តហើយ ពុំធ្លាស់ឆ្លើយសងវាចា នៅស្ងៀមដោយស្នេហា ពុំចរចាសងសាស័ព្ទ ៗ សេក ឈ្មោលយល់ស្ងៀមហើយ ពុំលង់ឡើយចរចូលឆាប់ លោត ឡើងជាប្រញាប់ ដើរជាន់ស្លាបបង្អើរហើយ ៗ ចំពុះចិក សិរសា ជាប់ហើយណាពុំលង់ឡើយ រួមរសមនោរម្យ ហើយ ដោយដំពើបទើបបានគ្នា ៗ ស្រយុតស្រយាលអង្គ ស្និទ្ធពិសវង់ពុំលាក់លា ប្រកៀកប្រកៀវគ្នា ជិតអង្គារួម ស្នេហ៍ស្នង ៗ សេកញីក្បួនខ្លួនណា ក្បួនធីតាជាម្ចាស់ហោង

សេកឈ្មោលភ្លេចច្បាស់ច្បង ស្ដេចគង់រង់ចាំមើលហើយ ៗ ឥឡូវគួរស្នេហ៍ស្ងួន ជួយគិតបងណាប្អូនអើយ ជៀតម្ចាស់បងនោះហើយ ស្ដេចចង់បានម្ចាស់នាងណា ៗ សិនបើម្ចាស់យើងបាន នៅមូលបាទរម្យស្នេហា ឯនាងនឹងបងណា យើងនៅមូលនឹងគ្នាហោង ៗ សេកញីលុះបានស្ដាប់ អស់សាសព្វខ្លោះហោង សេកញីឆ្លើយសាសង តបទៅបងសេកឈ្មោលថា ៗ ឱប្រុសថ្លៃសំឡាញ់ ម្ចាស់អ្នកមិញគង់ឯណា ប្អូនពុំយល់ក្សត្រា គង់ឯណាបង់យល់ហោង ៗ ទឹងបានថ្វាយបង្គំ ក្សត្រឧត្តមយល់ខ្ញុំផង បើច្នោះសូមអ្នកបង នាំប្អូនទៅបង្គំនៃ ៗ សេកឈ្មោលឮញីឆ្លើយ ថាច្នោះហើយនាំហើរខ្ញី ទៅដល់ព្រះជៀស្ដៃ គង់នៅព្រៃនោះហើយហោង ៗ សេកយល់ពោធិសត្វ ល្អលើសក្សត្រគ្រប់ស្រុកផង រូបតោមប្អឹតកក្ដង សមទឹងនាងនាថពេកក្រៃ ៗ ហើយសេកបង្គំក្សត្រ រូបស្រេចថ្វាត់ទើបជៀស្ដៃ មានព្រះបន្ទូលថា ទៅទឹងសេកគ្រេកគ្រាសថា ៗ អើអញអាគន្ធ៍

ទឹងសេកហោងបានគ្នាណា អរណាស់ឥតឧបមា ទឹងសេក
ណាបានគ្នានៃ ៗ វែងអញនេះណា យល់ពីតាធោម
ប្រវែត ចង់ស្គាល់នាមនាងនៃ នាមមាតាបិតាផង ៗ
សេកបានស្តាប់ទុក្ខ ចង់ស្គាល់ណាសេកទូលហោង ពីនាម
នាងនាថស្រីទួនល្អង ថាឈ្មោះសុវណ្ណបុប្ផា ៗ ព្រះវរ
បិតាទ្រង់ នាមសុរិវង្សនោះឯងណា ឯនាមព្រះមាតា
ឈ្មោះសុរិជាតិបុប្ផាផង ៗ វរវង្គពជនគរ ថ្កើងថ្កុំថ្កូរ
ធំកន្ទង នាមឈ្មោះវង្កតហោង ស្តេចរយឯកចំណុះ
នៃ ៗ ស្តេចស្តាប់សេកសាសង ទូលហើយហោងព្រះ
ជៀស្ពៃជ មានបន្ទូលទៀតនៃ ឲ្យសេកជួយគិតក្សត្រា ៗ
សេកអើយបើអញបាន នាងកល្យាណរួមស្នេហា មិត្រ
មូលទឹងគ្នាណា សេកទឹងនៅរួមគ្នាហោង ៗ ដូច្នោះ
បូរសេកឯង ខំខ្នះខ្នែងជួយអញផង ឲ្យអញទឹងទួនល្អង
បានគ្នាហោងរួមស្នេហា ៗ សេកទូលថាបពិត្រ ខ្ញុំម្ចាស់គិត
ជួយក្សត្រា កុំឲ្យព្រួយព្រះហា - ទ័យធានាខ្ញុំជួយហោង ៗ

ឲ្យបានក្សត្រទ្រង់ស័ក្តិ ស្និទ្ធរម្យកើតទឹងទូនល្អង កុំព្រួយព្រះ
ទ័យហោង ធានាជួយឲ្យបានវៃ ៗ សេកណាក្សត្របព្រាស់
ប្បង- ណាឈ្មោលផងហើរទៅខ្ញី បានដល់ធីតាស្រី
នាងនាថកំពុងក្រងផ្កា ៗ ផ្កានេះល្អប្រពៃ សមតែនៃ
ពាក់ហត្ថា សម្តេចព្រះកត្តា នោះសមណាស់ណាម្ចាស់
ថ្លៃ ៗ នាងស្តាប់ឮសេកថា ដូច្នោះណាស្រេចហើយ
នៃ នាងថាសេកស្រដី ហើរទៅលេងឯណាបាត់ ៗ យូរ
ហើយទើបឃើញមក ស្តីបំអកបំអន់ថ្ងាត់ ឡកឡឺយមកថា
ក្សត្រ ផាកស្តាពាក្យនោះសម ៗ ប្តីអញនៅឯណា កុំ
សេកថាក្រែងអញដំ ក្បាលបែកផាដំណាំ ទំថាអញវ៉ាយ
មិនខាន ៗ សេកយល់សៅឡឹកផង លេងឆ្ងាយហោងសេក
ឆ្លើយប្កាន ថាខ្ញុំម្ចាស់បាន យល់ស្វាមីម្ចាស់ផាក់ហើយ ៗ
ស្តេចផ្តាំទីងខ្ញុំផង មកទូលល្អងណាម្ចាស់អើយ ថាស្តេច
ទឹងមកហើយ ឲ្យម្ចាស់រៀបទទួលណា ៗ ខ្ញុំម្ចាស់នេះស្រដី
ពិតណាស់នៃទុំមោសា ខ្ញុំទៅឃើញក្សត្រា ស្តេចមកលប

មើលម្ចាស់ហោង ៗ ខ្ញុំយល់ស្ដេចនោះណា ដោយឆាយា
ល្អកន្លង ប្រុសក្នុងទ្វីបនេះហោង រកមកផ្ទឹមពុំបានឡើយ ៗ
ល្អស្មើនឹងទេព្ដា ល្អណាស់ណាម្ចាស់ខ្ញុំអើយ ស្ដេចហៅខ្ញុំ
ទៅហើយ ប្រាប់ទាំងឈ្មោះទាំងស្រុកផង ៗ ប្រាប់ឈ្មោះ
ព្រះបិតា ព្រះមាតាព្រះអគ្គហោង ហើយប្រើខ្ញុំមកផង
ឲ្យខ្ញុំមកទូលម្ចាស់នៃ ៗ នាងសុវណ្ណបុប្ផា ឮសេកថាដូច្នោះ
នៃ ព្រឺព្រួចក្នុងព្រះទ័យ មមៃគិតទៅក្សត្រា ៗ នាង
មានសុវណ្ណី សួរទៅនៃសេកវិញថា ស្ដេចនោះនៅ
ស្រុកណា នាមក្សត្រាឈ្មោះអ្វីហោង ៗ សេកទូលសព្វ
គ្រប់ហើយ ពុំលង់ឡើយទើបទូលល្អង នាងសួរសេកទៀត
ហោង ថាស្ដេចគង់នៅឯណា ៗ សេកទូលថាជៀសស្ល័យ
គង់នៅព្រៃមួយសាខា ក្រោមម្លប់ជ្រៃនោះណា អគ្គឯកានៅ
នោះហោង ៗ ម៉្លេះសមស្ដេចទន្ទឹង ខ្ញុំឯងនឹងយូរកន្លង
ថាបើម្ចាស់ព្រមផង ឲ្យខ្ញុំវិលទៅទូលឆាប់ ៗ ឯនាង
នាថនោះហោង ឮសាសទ៌សេកប្រាយប្រាប់ ថាស្ដេច

ចង់ដឹងឆាប់ ដូច្នេះហើយនាងថាអ៊ី ៗ បើអញឲ្យ
សេកនៅ កុំឲ្យទៅទូលឡើយនែ សមស្តេចអន់ព្រះ
ទ័យ ថាអញនេះចិត្តមិនបាន ៗ ទោះព្រមឬមិនព្រម
គួរឲ្យល្មមសមកល្យាណ គួរតែអញប្រែផ្កាន ឲ្យសេក
យកផ្កាកម្រង ៗ នេះទៅថ្វាយក្សត្រា តាមចិន្តាស្តេច
គិតហោង គិតស្រេចហើយនាងផ្សង អធិដ្ឋានសច្ចា
ថា ៗ បើស្តេចនោះឯងហោង ជាគូគ្រងនឹងអញណា
បើសេកបាននាំផ្កា អញទៅដល់កាលណាហើយ ៗ
កុំឲ្យស្តេចនោះនែ ចេញស្រដីសួរសេកឡើយ ឲ្យយកតែ
ផ្កាហើយ មានចិត្តគិតមកអញហោង ៗ ផ្សងស្រេច
នាងយកផ្កា កម្រងណាល្អឥតហ្មង បំពាក់សេកហើយហោង
នាងស្ងៀមពុំថាអ៊ីឡើយ ៗ សេកយល់នាងពិតា យក
ផ្កាពាក់ដូច្នោះហើយ នាំផ្កាពុំលង់ឡើយ ហើយទៅ
ថ្វាយក្សត្រានែ ៗ មើលយល់ពោធិសត្វ គង់ស្ងៀម
ស្តាប់មើលទៅវៃ បានដល់ព្រះជៀស្ដ៏យ ទតមក

យល់កម្រងផ្កា ៗ ពន្ធពាក់នៅករសេក ល្អបំផ្លែកពេញចិន្តា
ស្តេចយកកម្រងផ្កា ពីកសេកគន់សៀមហោង ៗ ស្តេចគន់
នៅសៀមស្ងាត់ ដូចសង្ហានាងនាថផ្សង សេកយល់ដូច្នោះហោង
សេកសោកណាហើរចេញទៅ ៗ បានជួបនឹងគ្នាណា
ឈ្មោលសួរថានែប្អូនទៅ ដូចម្តេចកាលនាងទៅ ទូលម្ចាស់
នាងនោះថាអ្វី ៗ សេកញីប្រាប់ឈ្មោលថា នាងពីតាសត្វ
សេចក្តី ពុំមានសល់ឡើយនៃ ការកិច្ចអ្វីគ្មានសល់ឡើយ ៗ
ឈ្មោលថាឱមាសមិត្រ ស្តេចចូលចិត្តនឹងគ្នាហើយ បើពុំ
ចូលចិត្តឡើយ នោះពុំឲ្យផ្កាកម្រង ៗ បងនឹងនាំក្សត្រា
យប់នឹងណាទៅដល់ហោង ប្អូនអើយនៅចាំបង បងទៅ
រកនាងឯណា ៗ នឹងនាំក្សត្រពីរពង្ស មូលកិស្សវង្សរួម
ស្នេហា ឯបងនឹងនាងណា បានរួមរក់នឹងគ្នាហោង ៗ
ញីស្តាប់ឈ្មោលផ្តែផ្តាំ ចងចិត្តចាំបណ្តាំផង ស្រេចហើយ
លាឈ្មោលហោង ហើរទៅថ្កូននាងនាថនៃ ៗ ដល់
ហើយមើលទៅយល់ នាងនិម្មលចូលទៅវៃ ៗ សុវណ្ណ

បុប្ផាថៃ យល់សេកមកដល់ហើយណា ៗ នាងមានសុវណ្ណី ពោមពើតស្តីដណ្តឹងថា សេកនាំកម្រងផ្កា ថ្វាយក្សត្រា នោះជាអ្វី ៗ សេកទូលនាងវិញថា ខ្ញុំនាំផ្កាទៅដល់ទ្វី ស្តេចយល់ហើយពុំស្តី យកតែផ្កាពីខ្ញុំទៅ ៗ ពុំមានពាក្យ អ្វីថា មួយម៉ាត់ណាគន់ស្ងៀមនៅ ស្តេចយកតែផ្កាទៅ គន់ស្ងៀមនៅពុំស្តីឡើយ ៗ នាងស្តាប់សេកទូលថា មហាក្សត្រាស្ងៀមប្ដោះហើយ ថាស្តេចពុំស្តីឡើយ នាងនាថថា គួរព្រេងផង ៗ ហើយនាងគន់គិតថា អញ្ញនេះណាសង្វាផ្សង មិនឲ្យស្តេចស្តីហោង ត្រូវបានដូចសង្វា ៗ កាលនោះនាងនាថថៃ ពុំស្រដីស្ងៀមហើយណា សេកសោកពុំចរចា នៅស្ងៀមស្ងាត់ពុំសាសង ៗ

បែរបទភុជុងលីលា កាលនោះនាងនា នាំស្រីពាំងឡាយ ៗ ត្រេកសាលជាសុខសប្បាយ ទត់ឈើពាំងឡាយ ទីងអស់ស្រីផង ៗ រីឯនាងនាថទូនល្អង បុប្ផាទងរ៉ង យល់ព្រះសុរិយា ៗ ឲ្យទឹមកងរថា ស្រេចស្រាប់ហើយណា នាងឡើងគន់ហោង ៗ

អស់ទាំងស្រីសៅឡឹកផង ទឹមរថគ្រប់ហោង រៀនជិះហើយ
ណា ៗ ទើបអស់ពួកពលអាសា មន្ត្រីសេនា រៀបហែ
នាងនៃ ៗ ចេញចាកព្រះពន្លាវៃ ហែរហួសផុតព្រៃ ដល់
នៃកំពង់ហោង ៗ ដល់ប្រាសាទនាងជាម្តង គង់បន្ទប់ហោង
បង្គំបិតា ៗ បង្គំព្រះវរមាតា សំណេះសួរសា សព្វគ្រប់
ហើយហោង ៗ សុវណ្ណបុប្ផាទូលល្អង បង្គំលាហោង នាំ
សៅឡឹកនៃ ៗ មកប្តានប្រាសាទវិញវៃ អស់សៅឡឹកនៃ ហែ
នាងមកណា ៗ បានដល់មណ្ឌលប្រាង្គប្រាសាទហើយ
ធីតា ដាក់អង្គុយហោង ៗ នាងផ្ទំម្នាក់ឯងឥតហ្មង គិត
ទៅព្រះបង ស្តេចគង់ឯកា ៗ ឯកអង្គគង់ក្នុងព្រឹក្សា
គិតក្រែងក្សត្រា ស្តេចពុំមកឡើយ ៗ នាងគិតទៅ
ក្សត្រណាស់ហើយ ផ្ទុំពុំលក់ឡើយ នាងគិតថាគួរព្រួង
ហោង នាងនឹងគិតទៅព្រះបង ផ្ទុំពុំលក់ហោងនឹងគិត
ណាស់ណា ៗ ឯអង្គក្សត្រទ្រង់បេស្ដា ក្រោយនាងនោះ
ណា ហៅសេកមកហើយ ៗ ត្រាស់ថាឥឡូវសេកកើយ

នាងទៅបាត់ហើយ យើងទៅតាមហោង ៗ សេកសោកខ្លាស់ ឆ្លើយសាសន៍ ថាអញ្ជើញទូលល្អង តាមព្រះចិន្តា ៗ អញ្ជើញ ស្តេចប្រែកាឡា ជាសេកហើយណា ទីងហើរទៅហោង ៗ កាលនោះក្សត្រថ្ងៃច្បាស់ច្បង ស្តេចកាឡាហោង ជាសេក ហើយណា ៗ ហើរស្ទុះផ្តក់ផ្ទុះលើកា - កាសផាប់សោះ សា លឿនខ្លាំងដាងខ្យល់ ៗ ផ្តក់ផ្ទុះតែងទៅដល់ ក្រុងត្រៃ សាគល វត្តនោះណា ៗ ហើរវង់រកក្នុងប្រាង្គប្រា - សាទនាងនោះណា ពិតពុំឃើញឡើយ ៗ សេកស្រែក ទ្រញើញហើយ ញីពុំលង់ឡើយ ហើរចេញម្នម្នា ៗ មក ក្រៅបានជួបនឹងគ្នា ពុំយល់ពជា យល់ឯសេកហោង ៗ ល្អក្រៃប្រពៃកន្ទង់ ញីសួរឈ្មោលផង ឈ្មោលនោះប្រាប់ ថា ៗ ព្រះអង្គស្តេចប្រែកាឡា ជាសេកមកណា រក ម្ចាស់ប្អូនហោង ៗ សេកញីអរពេកកន្ទង់ នាំស្តេចទៅ ហោង ដល់ព្រះសៅវិតា ៗ ហើយសេកទូលពោធីថា នាងនាថធីតា ជុំនៅនេះហោង ៗ អញ្ជើញក្សត្រថ្ងៃច្បាស់

បួន ចៅថ្កានទានហ៊ាន នាងខ្ញុំហើយនៃ ៗ កាលនោះ ព្រះបាទជៀស្ឌដៃ ស្ដេចបរបួលវៃ គាមនៃកៅតែ ៗ យល់ នាងខ្ញុំក្លូចកាយា ស្ដេចប្រែកាឡា ពីសេកឆាប់ខ្ញុំ ៗ ជាអគ្គ ក្សត្រទ្រង់បរមី ឆោមឆើតពីសី ដូចអគ្គបុទ្រា ៗ អស់អគ្គ ត្រយង់សោភា នៅទិញទៅ ផ្ទឹមផង់ពុំបាន ៗ ស្ដេច គង់ខាងនាងកល្យាណា គន់អស់អគ្គព្រាណា ប្រកបគ្រប់ លក្ខណ៍ ៗ ស្ដេចគន់មើលនាងយ៉ាងណាក់ ប្រកបគ្រប់លក្ខណ៍ គ្រប់បញ្ចស្ត្រី ៗ

ថៃបឋកាកកាល ពីអគ្គក្សត្រា គង់ខាងទេវី ស្ដេចគន់រឹង គន់ អស់អគ្គស្ត្រី សម្ដេចភូមី គន់ផល់បាត ៗ គន់ហើយរឹង គន់ រូបកង់ល្អតល្អន់ ល្អល្អះសោភា ស្ដេចគន់ពិតពី កេសីអ្នប ភ្វា ដូចស្វាបកមក ខ្មៅខ្ញាញ់ផ្តុកជិត ៗ មង់គន់មើលណា នៃ ព្រះភក្ត្រា មាសមៃរមមិត្រ រាក់ដូចពពិល ស្រស់ស្រិលពិចិត្ត ដូចមាសមិញមិត្រ ក្រោងព្រាយរស្មី ៗ ភូម្មាទ្រទ្ទួយ ដូចកល់បង់គួយ កៅវតានពីសី ផ្កាល់តាំងសន្ខាង ដូច

មាសឲ្យដី ដាំងទើបធ្វើថ្មី ស្រស់ស្រិលល្អគ្រាត់ ៗ ព្រះ ឱស្ឋប្រិមប្រិយ សុរង់ផ្ចត់បី ដូចគេដុះខាត់ អង្រ្គួរគាង ពងរៀវ ល្អក្រាត់ សុដនបួនរ័ត្ន បីដូចកល់ផ្កា ៗ ឈូកប៉ុបក្រពុំ បងមើល ទៅសម លេបពីឧក ហត្ថាសរស្រួល មូលសមទឹងស្នា ម្រាមនៃហត្ថា ដូចបន្ទាក្រូច ៗ ចង្កេះរៀវខ្ញុំ ល្អណាស់ ស័ក្តិសម គ្មានស្រីណាដូច មិនខ្ពស់មិនទាប មិនធំ មិនតូច រកមកប្រដូច មួយមិនមានឡើយ ៗ ស្ដេចបើក ព្រះភ័ស្ត្រ នោះនៃចេញអស់ ពីអង្គនាងហើយ ស្ដេចប្រាស់ ផ្ទុំផ្ទាប់ ពិតពុំលង់ឡើយ ផ្ទុំឱបនាងហើយ លើខែន សេយ្យនា ៗ ប្រទីបភ្លឺព្រាត ភ្លឺក្នុងប្រាសាទ ដូចថ្ងៃរះ សា រីឯនាងនាថ ភ្ញាក់ភ្ញាក់កាយា យល់ឯក្សត្រា ឱបអង្គ នាងនៃ ៗ នាងនាថទៅ កិតញ័រត្តី ទឹងព្រះជេស្ឋ ជ័យ នាងពុំហ៊ានក្រោកសំងឹងញៃ ក្រែងព្រះជេស្ឋ ជ័យ ផ្ទុំពុំលក់ឡើយ ៗ នាងនាថធីតា ឥតឲ្យក្សត្រា ផ្ទុំ កៀបអង្គឡើយ នាងនាថសំងំ ពុំកម្រើកឡើយ សំងំយូរ

ហើយ ពាល់តែក្សត្រា ៗ ផ្ដុំគ្រួសក្ដៅកាយ នាងនាថផោម

ឆាយ ថ្នមលើកហត្ថា យកចេញពីអង្គ នៃនាងហើយណា

ដាក់ព្រះហត្ថា លើខ្នើយឧបនៃ ៗ ហើយនាងនារី ក្រោកចេញ

អំពី ខាងព្រះជៀស្ដជ័យ ' នាងនាថលបលួច គន់អស់អង្គនៃ

យល់ព្រះជៀស្ដជ័យ ផោមផើតថ្ងៃថ្វា ៗ ថាឆ្នើមប្រុសផង

ល្អក្រៃកន្ទង់ លើសលែងទេព្ដា នាងគន់សព្វហើយ រំពឹងគិត

ថា គួរដាស់ក្សត្រា រឭកឡើងខ្ញុំ ៗ នាងនាថទេវី ទឹងព្រះ

ភូមី ខ្លាស់ព្រះចក្រី ពាល់ណាស់ខំល្បុក ហត្ថាទៅខ្ញុំ ពាល់

ទាបតី តើនទៀងពីផ្ទុំ ៗ នាងស្ដួរក្សត្រថ្ងៃ ម្ដេចហ៊ានពេកក្រៃ

បរបួលមកផ្ទុំ ពុំមានគិតក្រែង វេងវិរវម្យ ពឹងពិបត្ដិខ្ញុំ ក្រែង

ព្រមពុំព្រម ៗ ដូចោ្នះពុំសម គួរក្សត្រឧត្ដម ស្ដេចធ្វើឲ្យល្មម ពោះ

ស្រួលពុំស្រួល ទោះព្រមពុំព្រម គួរធ្វើឲ្យល្មមឲ្យសមសេចក្ដី ៗ

---

(សង្ខេប ទឹងមានខ្សែ៤ចប់) សូមអានរឿងនាងសុ-
វណ្ណផល្លា ទិញជាវរឿង ជាខ្សែរឿងយ៉ាងកំសត់ក្នុងការផ្សងព្រេង
បណ្ណាគារសុ-ជីវិត

២.៣.៤.១ ទំ ស្រីខ្មុក ៣.

៤ . ១ ទំ ស្រូវស្រែទឹក          ៣.៤.១ ទំ ទឹកទន្លេគុក.

ខាងក្រោយ (២៥) . ៤ . ១ ទំ ដំណាំ

# [illegible]

ខាងក្រោយ ២ ទំ ទឹកទន្លេគុក ៦.៨ ទំ ស្រីខ្មុកលំអទុមានទៀត

២.៣ ទំ ... ទឹក, ស្រីកសិករ, ស្រីតែតគោក, ទំនៀមទម្លាប់ទៀត

, [illegible] , [illegible] , [illegible] , [illegible]

ស្រីខ្មែរទៀត ៩ . [illegible]

[illegible]

[illegible]

[illegible]          [illegible]

# សៀវភៅដែលផ្សាយចេញពីបណ្ណាគារសុជីវិត

ការតស៊ូ ទី ១ - ២ - ៣   មហាឃាតកម្ម   ស្នេហ

ផ្លូវទឹក ទី ៣ ចប់ សឹង - ឡាយ   ស្នូរកាំភ្លើងក្រោយសង្គ្រាម

ម៉ុំនីកាល័យ , នារីពេជ្រ , ការមិត្តភាព គិម - សែត

ទស្សនាវដ្ដីជីវិត និពន្ធបម្រុះ ព្រះលក្ខណ៍សុខវង្ស ទី១.២.៣.៤

ទី៥.៦.៧ សុគន្ធរោជន៍ទី ១ - ២ - ៣   ភូមិម៉ាឡៃ ទី ១ . ២

ម៉ាក់ថឺន ទី ១ . ២ . (ចប់) សុជីវិត

# សៀវភៅដែលចេញមកពីរោងពុម្ពទៀត

ព្រះលក្ខណ៍សុខវង្ស ទី ៨ - ៩ សុគន្ធរោជន៍ទី

ព្រហ្មទិន្នឈ្មោះក្រេន , អនាគតវង្ស , ពោធិវង្ស , ភូមិតាំ

សុវណ្ណផល្លា , ល្បើកដុំ , តាអត់ , ក

បុប្ផាវណ្ណវង្ស ឡុកិណ្ណវង្ស លេណារ៉ា - តាតិសុសិក្ខ . ។

ចៅវៀង - បំពេញករណីយកិច្ចមិនកើតស្នេហា . លោកសុគតៃ

សូមរកទិញតាម ទីដែលចេញពីបណ្ណាគារសុជីវិតជាប់នេះ

---

រោងពុម្ពបុញ្ញាចារ្យ   តម្លៃ១២រ០០